ទស្សនាវដ្ដី
សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ

# ប្រទេសកម្ពុជា ខែឧសភា ឆ្នាំ១៩៧០

## សេចក្ដីរាយការណ៍រៀបចំឡើងដោយបុគ្គលិក សំរាប់ការប្រើប្រាស់នៃគណៈកម្មាធិការព្រឹទ្ធសភា ផ្នែកទំនាក់ទំនងការបរទេសសហរដ្ឋអាមេរិក

(បោះពុម្ពផ្សាយនៅថ្ងៃទី៧ មិថុនា ឆ្នាំ១៩៧០)

(បកប្រែក្រៅផ្លូវការ)

## មាតិការរឿង


១- បុព្វកថា
២- លិខិតបញ្ជូន
៣- ព្រឹត្តិការណ៍បន្តបន្ទាប់ចាប់តាំងពីការធ្លាក់ពីអំណាចនៃសីហនុ
៤- ទស្សនៈពីរដ្ឋាភិបាលក្រុងសៃហ្គង
៥- ទស្សនៈពីរដ្ឋាភិបាលក្រុងភ្នំពេញ
៦- អាថ៌កំបាំងនៃជំនួយយោធាដល់កម្ពុជា
៧- ការសម្លឹងមើលទៅខាងមុខ


❑

## បុព្វកថា

មួយអាទិត្យមុនពេលអន្តរាគមន៍អាមេរិកាំងនិងវៀតណាមខាងត្បូងនៅកម្ពុជា, គណៈកម្មាធិការផ្នែកទំនាក់ទំនងការបរទេស បានសុំបុគ្គលិកខាងផ្ដល់យោបល់ពីរនាក់គឺ លោក James G. Lowenstein និងលោក Richard M. Moose ឲ្យធ្វើដំណើរទៅកាន់ប្រទេសកម្ពុជានិងវៀតណាមដើម្បីផ្ដល់ដល់គណៈកម្មាធិការនូវពត៌មានជាដំបូងដៃ អំពីការវិវត្តន៍កើតឡើងនៅទីនោះ ។ ទង្វើនៃគណៈកម្មាធិការបានបង្ហាញឲ្យឃើញនូវចំណាប់អារម្មណ៍ ទៅលើលទ្ធភាពនៃការចូលទៅជាប់ពាក់ព័ន្ធនៃសហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា ហើយនិងការមិនពេញចិត្តទៅនឹងកង្វះការផ្ដល់យោបល់ពីខាងផ្នែកនីតិប្រតិបត្តិ ។ នៅពេល លោក Lowenstein និងលោក Moose បានទៅដល់វៀតណាម, កងទ័ពអាមេរិកាំងនិងវៀតណាមខាងត្បូង ក៏បានធ្វើការប្រយុទ្ធនៅលើទឹកដីខ្មែររួចទៅហើយ ។

ពេលស្ថិតនៅវៀតណាមនិងកម្ពុជា, លោក Lowenstein និងលោក Moose មានលទ្ធភាពអាចផ្ញើនូវសេចក្ដីរាយការណ៍សម្ងាត់ជាបន្តបន្ទាប់គ្នាដល់គណៈកម្មាធិការ ដែលជាពត៌មានបន្ថែមទៅលើពត៌មានគណៈកម្មាធិការបានទទួលតាមរយៈកាសែត និងបានមកពីផ្នែកនីតិប្រតិបត្តិ ។

នៅពេលលោកទាំងពីរវិលត្រឡប់មករដ្ឋធានីវ៉ាស៊ីនតោនវិញ លោក Lowenstein និងលោក Moose បានរាយការណ៍ដល់សម័យប្រជុំពេញអង្គនៃគណៈកម្មាធិការចាត់ចែង។ សមាជិកនៃគណៈកម្មាធិការបានសំរេចចិត្តថា អ្វីៗដែលបុគ្គលិកយល់ដឹង អាចនិងត្រូវចែកជូនផ្សាយដល់សាធារណជនអាមេរិកាំងផងដែរ នេះបើយោងតាមលោក Lowenstein និងលោក Moose ដែលត្រូវគេសុំឲ្យបើកបង្ហាញអំពីសេចក្ដីរាយការណ៍សម្ងាត់ទាំងអស់នោះ ។

កាលពីខែកុម្ភៈកន្លងមក, នៅក្នុងសេចក្ដីរាយការណ៍បន្ទាប់ពីដំណើរដូចគ្នាទៅវៀតណាម, លោក Lowenstein និងលោក Moose បានសរុបថា សង្គ្រាមនៅវៀតណាមមើលទៅហាក់ដូចជា «មិនគ្រាន់តែឆ្ងាយពីជ័យជំនះប៉ុណ្ណោះទេ តែនៅឆ្ងាយពីចប់ទៅទៀត» ។ សង្គ្រាមនៅវៀតណាម, នៅឆ្ងាយពីចប់នៅឡើយ ហើយឥឡូវនេះកំពុងរាលដាលឆ្លងចូលទៅប្រទេសកម្ពុជា ។ មន្ត្រីអាមេរិកាំងម្នាក់ពេលនោះ មានម្ដងនិយាយថា នៅវៀតណាម, យើងត្រូវតែកំទេចទីក្រុងមួយចោលដើម្បីគ្រាន់តែសង្គ្រោះជីវិត ។ ខាងរដ្ឋាភិបាលពេលនេះតវ៉ាថា វាជាការចាំបាច់ណាស់ដែលគេត្រូវពង្រីកសង្គ្រាមដើម្បីនឹងបញ្ចប់សង្គ្រាម ។

សេចក្ដីរាយការណ៍ធ្វើឡើងដោយលោក Lowenstein និងលោក Moose ដែលផ្អែកទៅលើការពន្យល់ប្រាប់យ៉ាងសង្ខេបនៅរដ្ឋធានីវ៉ាស៊ីនតោន និងការសង្កេតឃើញរបស់គាត់នៅវៀតណាម, នៅភ្នំពេញ និងនៅទីក្រុងប៉ារីស, គឺនឹងរៀបរាប់អំពីព្រឹត្តិការណ៍កើតឡើងជាបន្តបន្ទាប់គ្នា ដែលបណ្ដាលឲ្យសង្គ្រាមកាន់តែរីកធំឡើងៗ ។ សេចក្ដីរាយការណ៍នឹងអធិប្បាយអំពីស្ថានភាពនៅដើមខែឧសភា ចេញមកពីទស្សនៈដ៏មានខ្លឹមសារប្លែកៗគ្នាពីសៃហ្គងនិងភ្នំពេញ ទាក់ទងទៅនឹងការលំបាកដែលពួកគេពើបប្រទះ និងដែលពួកគេបានកត់សំគាល់ឃើញជាទូទៅ អំពីជំនួយសហរដ្ឋអាមេរិកទៅដល់រដ្ឋាភិបាលខ្មែរ ។ សេចក្ដីរាយការណ៍នឹងបើកបង្ហាញឲ្យឃើញផងដែរ អំពីចំណាប់អារម្មណ៍របស់ពួកគេ ទាក់ទងនឹងការវិវត្តន៍ទៅអនាគតនៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំជឿថា សេចក្ដីរាយការណ៍របស់ពួកគេ នឹងបានជាជំនួយបន្ថែមទៅលើពត៌មានផ្សាយជាសាធារណៈ សំរាប់ខែចំបូងនៃអ្វីដែលគេហៅនៅក្នុងពេលឥឡូវនេះថា សង្គ្រាមទីពីរនៃឥណ្ឌូចិន ។

J. W. Fulbright

❑

## លិខិតបញ្ជូន

ថ្ងៃទី៣ មិថុនា ឆ្នាំ១៩៧០

លោកប្រធានជាទីរាប់អាន,

នៅចុងខែមេសាកន្លងមកនេះ, បន្ទាប់ពីសេចក្ដីរាយការណ៍ពត៌មាននិយាយថា រដ្ឋាភិបាលកំពុងស្ថិតនៅក្រោមការសិក្សា អំពីសំណូមពរផ្ដល់ជំនួយយោធាដល់រដ្ឋាភិបាលខ្មែរ, លោកប្រធានបានសុំឲ្យយើងខ្ញុំធ្វើដំណើរទៅវៀតណាមនិងកម្ពុជា ។ ក្នុងសេចក្ដីប្រកាសឲ្យដឹងអំពីការធ្វើដំណើររបស់យើងខ្ញុំ, លោកប្រធានបានគូសបញ្ជាក់ថា សេចក្ដីរាយការណ៍ពត៌មានបែបនេះមានសារប្រយោជន៍ខ្លាំងណាស់ ពុំមែនគ្រាន់តែជាប្រភពពត៌មានសំរាប់ចែកចាយដល់សមាជិកនៃគណៈកម្មាធិការផ្នែកទំនាក់ទំនងការបរទេសប៉ុណ្ណោះទេ ហើយលោកប្រធានមានប្រសាសន៍ថា លោកប្រធានយល់ព្រមបញ្ជូនយើងខ្ញុំ ឲ្យទៅធ្វើសេចក្ដីរាយការណ៍ត្រឡប់មកជូនគណៈកម្មាធិការវិញ អំពីស្ថានភាពជាទូទៅនៅក្នុងប្រទេសកម្ពុជា និងជាពិសេសអំពីបញ្ហាទាក់ទងទៅនឹងសំណូមពររដ្ឋាភិបាលខ្មែរ សុំជំនួយយោធានិងជំនួយអាមេរិកាំងផ្សេងៗទៀត ដែលសហរដ្ឋអាមេរិកមាន

ការជាប់ពាក់ព័ន្ធសកម្មភាពយោធាបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ដោយចំពោះនិងដោយមិនចំពោះ ហើយនិងអំពីប្រសិទ្ធិភាពនៃការវិវត្តន៍ថ្មីៗនៅកម្ពុជាទៅលើសង្គ្រាមនៅវៀតណាម ព្រមទាំងសេចក្តីសង្ឃឹម បើប្រសិនណាអាចកើតមាន អំពីការចរចាសំរុះសំរួលនយោបាយ ។

នៅពេលយើងខ្ញុំទៅដល់ទីក្រុងសៃហ្គងថ្ងៃទី៤ឧសភា, កម្លាំងទ័ពអាមេរិកាំងបានធ្វើប្រតិបត្តិការផ្ទាល់នៅក្នុងស្រុកខ្មែររួចទៅហើយ ។ជំនួយយោធារបស់អាមេរិកាំងខ្លះក៏បានទៅដល់ទីក្រុងភ្នំពេញផងដែរ ។ សេចក្តីរាយការណ៍របស់យើងខ្ញុំមានរួមទាំងការសង្កេតមើលអំពីប្រតិបត្តិការនៃវៀតណាមខាងត្បូងនិងសហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា, អំពីជំនួយសហរដ្ឋអាមេរិកផ្តល់ជូនរដ្ឋាភិបាលខ្មែរ និងអំពីលទ្ធផលយោធានិងនយោបាយក្នុងរយៈពេលវែងនៃព្រឹត្តិការណ៍នេះ ។

យើងខ្ញុំបានចាកចេញពីរដ្ឋធានីវ៉ាស៊ិនតោនពីថ្ងៃទី២៩មេសា រួចហើយត្រឡប់មកវិញនៅថ្ងៃទី១៥ឧសភា, បានចំណាយពេល២ថ្ងៃនៅវៀតណាមមុនពេលបន្តដំណើរទៅកាន់ប្រទេសកម្ពុជា, ៦ថ្ងៃនៅទីក្រុងភ្នំពេញ, ២ថ្ងៃថែមទៀតនៅវៀតណាម និង២ថ្ងៃនៅទីក្រុងប៉ារីស ។ នៅវៀតណាម, យើងខ្ញុំបានទទួលនូវសេចក្តីរាយការណ៍សង្ខេបនៅសេនាធិការដ្ឋានបញ្ជាការជំនួយយោធាសហរដ្ឋអាមេរិកនៅវៀតណាម (U.S. Military Assistance Command, Vietnam -MACV) និងបានចំណាយពេលពេញ២ថ្ងៃទស្សនាទីកន្លែងប្រតិបត្តិការអាមេរិកាំងនិងវៀតណាមខាងត្បូង នៅក្នុងតំបន់«ផ្លែសន្ទូច» (Fishhook) និងតំបន់«ចំពុះសេក» (Parrot's Beak) ព្រមទាំងទីកន្លែងផ្សេងទៀតនៅក្នុងទឹកដីខ្មែរ ។ នៅទីក្រុងសៃហ្គង, យើងខ្ញុំក៏បានទទួលនូវសេចក្តីរាយការណ៍សង្ខេបផងដែរពីមេអគ្គបញ្ជាការនៃប្រតិបត្តិរួមគ្នាវៀតណាម រួចហើយយើងខ្ញុំបានជួបជាមួយពួកមន្ត្រីស៊ីវិលវៀតណាម, ពួកអ្នកទទួលខុសត្រូវកិច្ចការរបស់យើង ព្រមទាំងពួកមន្ត្រីការទូត និងពួកអ្នកកាសែតផ្សេងៗទៀត ។

នៅទីក្រុងភ្នំពេញ, យើងខ្ញុំបានជួបពិភាក្សាគ្នាយ៉ាងលំអិតជាមួយអនុព័ន្ធយោធាប្រចាំស្ថានទូតអាមេរិកាំង, ពួកមន្ត្រីខ្មែរដែលមានរួមទាំងឧបនាយករដ្ឋមន្ត្រីទី១ទ្រង់ស៊ីសុវត្ថិ-សិរិមតៈ, រដ្ឋមន្ត្រីក្រសួងការបរទេសយ៉ែម-សំបូរ, ឧត្តមសេនីយ៍អ៊ុយ-សយ, មេអគ្គបញ្ជាការកងទ័ព, ពួកសមាជិកសភាខ្មែរ, ពួកអ្នកការទូតបរទេស, ពួកសាស្ត្រាចារ្យ និងពួកអ្នកកាសែតអាមេរិកាំងនិងបរទេស ។ យើងខ្ញុំបានជួបនៅទីក្រុងប៉ារីសជាមួយមេដឹកនាំគណៈប្រតិភូអាមេរិកាំងស្ដីទី សំរាប់កិច្ចចរចាទីក្រុងប៉ារីស ហើយនិងសមាជិកអ្នកជំនាញការម្នាក់នៃឥណ្ឌូចិន ។

សេចក្តីរាយការណ៍របស់យើងខ្ញុំផ្អែកទៅលើ ការបង្ហាញដោយនិយាយប្រាប់ផ្ទាល់មាត់ជូនដល់គណៈកម្មាធិការ នៅក្នុងសម័យប្រជុំអ្នកចាត់ចែង កាលពីថ្ងៃទី២១ឧសភា ។ យើងខ្ញុំបានតាមដានការអនុវត្តន៍មុនៗ ដើម្បីចៀសវាងការទម្លាក់កំហុសដោយឥតមូលហេតុ ។

ដោយសេចក្តីរាប់អាន,

**James G. Lowenstein**

**Richard M. Moose**

❑

## ព្រឹត្តិការណ៍បន្តបន្ទាប់ចាប់តាំងពីការធ្លាក់ពីអំណាចនៃសីហនុ

ជំហានទីមួយនៃការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ហើយនិងហេតុផលដែលកើតឡើងទៅអនាគត គឺការទទួលស្គាល់ថា មានបែបផែនសកម្មភាពនិងប្រតិកម្ម ទៅនឹងព្រឹត្តិការណ៍កើតមានឡើងជាបន្តបន្ទាប់គ្នាក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ ។ កាលប្រវត្តិបន្ទាប់ទៅនេះ ប្រហែលមិនមានន័យជ្រៅជ្រះបង្ហាញឲ្យឃើញ អំពីព្រឹត្តិការណ៍គាប់ជួនកើតឡើង និងអំពីលក្ខណៈពាក់ព័ន្ធគ្នាទៅវិញទៅមក នៃប្រតិបត្តិការឆ្លងព្រំដែនធ្វើឡើងដោយកម្លាំងទ័ពវៀតណាមខាងត្បូង - សកម្មភាពចេញពីជំរកយ៉ាងជ្រៅចូលទៅក្នុងទឹកដីខ្មែរនៃកងទ័ពវៀតណាមខាងជើងនិងវៀតកុង - អាកប្បកិរិយានៃរដ្ឋាភិបាលខ្មែរ ឆ្ពោះទៅរកវៀតណាមខាងជើងនិងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន - ប្រព្រឹត្តិកម្មទៅលើពួកអាណិកជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា - ហើយនិងប្រតិកម្មរបស់ហាណូយ, ប៉េកាំង, ម៉ូស្គូ, សៃហ្គង និងវ៉ាស៊ិនតោន ។

### ខែមិនា

ថ្ងៃទី៨មិនា គឺជាចំណុចយ៉ាងល្អនៃការចាប់ផ្តើមពិនិត្យមើលនៃព្រឹត្តិការណ៍ដែលបានកើតឡើង ។ នៅថ្ងៃនេះ, គឺ១០ថ្ងៃមុនពេលផ្លាស់ប្តូរតំណែងសីហនុពីប្រមុខរដ្ឋ, បាតុកម្មបានផ្ទុះឡើងជាច្រើនកន្លែងនៅតាមតំបន់ព្រំដែនខ្មែរ ប្រឆាំងវត្តមាននៃកងទ័ពវៀតណាមខាងជើង - បាតុកម្មនេះ ត្រូវបានមើលឃើញស្ទើរតែពិតប្រាកដ រៀបចំឡើងដោយពួកមេដឹកនាំនៃរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ។ បាតកម្មធ្វើបន្តរហូតដល់ថ្ងៃទី១០មិនា។ ថ្ងៃបន្ទាប់មក, ស្ថានទូតវៀតណាមខាងជើង និងស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៅភ្នំពេញ បានត្រូវបំផ្លិចបំផ្លាញដោយក្រុមបាតុកររៀបចំឡើងដោយពួកមេដឹកនាំរដ្ឋាភិបាលខ្មែរឥឡូវនេះផងដែរ ។

ស្តេចសីហនុ, ដែលនៅក្នុងតួនាទីជាប្រមុខរដ្ឋនៅឡើយ, ពុំស្ថិតនៅក្នុងស្រុកខ្មែរទេនាពេលនេះ ។ ព្រះអង្គបានចាកចេញតាំងពីដើមខែមករាម៉្លេះទៅប្រទេសបារាំង ។ នៅក្នុងរដ្ឋធានីខ្មែរ, កិច្ចការរដ្ឋាភិបាលស្ថិតនៅក្រោមការដឹកនាំផ្ទាល់នៃនាយករដ្ឋមន្ត្រីលន់-នល់ និងឧបនាយករដ្ឋមន្ត្រីទី១សិរិមតៈ ។ ថ្ងៃទី១២មិនា, លន់-នល់, ក្នុងនាមរដ្ឋាភិបាលបានចេញនូវឱសានវាទមួយ ទាមទារឲ្យកងទ័ពវៀតណាមខាងជើងនិងវៀតកុងដកថយចេញពីប្រទេសកម្ពុជា ក្នុងរវាង៧២ម៉ោង ។ ហើយនៅក្នុងពេលជាមួយគ្នានេះផងដែរ, សិរិមតៈបានលប់ចោលសន្ធិសញ្ញាជំនួញ រវាងកម្ពុជានិងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន ។

ថ្ងៃទី១៣មិនា, ស្តេចសីហនុ, បន្ទាប់ពីប្រកាសថា ព្រះអង្គមិនព្រមទទួលក្រុមបេសកកម្ម ដែលលន់-នល់និងសិរិមតៈបានស្នើបញ្ជូនឲ្យទៅគាល់ព្រះអង្គ, បានយាងចាកចេញពីទីក្រុងប៉ារីស និងទៅដល់ទីក្រុងម៉ូស្គូក្នុងដំណើរទៅកាន់ទីក្រុងប៉េកាំង ។ ជាទូទៅគេបានទទួលយល់ឃើញថាវត្ថុបំណងរបស់ព្រះអង្គយាងទៅកាន់ទីក្រុងម៉ូស្គូនិងទីក្រុងប៉េកាំង ជាជាងវិលត្រឡប់យ៉ាងប្រញាប់មកទីក្រុងភ្នំពេញ, គឺដើម្បីសុំឲ្យសូវៀតនិងចិន ប្រើឥទ្ធិពលរបស់ខ្លួនបញ្ចុះបញ្ចូលវៀតណាមខាងជើង ធ្វើសម្បទានខ្លះទាក់ទងទៅនឹងការប្រើប្រាស់ទឹកដីកម្ពុជា ។

ថ្ងៃទី១៥មិនា, ឱសានវាទរបស់លន់-នល់បានផុតកំណត់, ការទាមទារក៏ពុំបានសំរេច ។ ក្នុងថ្ងៃដដែលនេះ, កងទ័ពវៀតណាមខាងត្បូងបានផ្តល់ការគាំទ្របាញ់កាំភ្លើងធំ តាមការសុំពីកងទ័ពខ្មែរ ។ ថ្ងៃទី១៦មីនា, គេឃើញមានការជួបគ្នាជាលើកទី១ និងជាផ្លូវការដែលគេបានដឹង នៅទីក្រុងភ្នំពេញ នៃពួកតំណាងខាងខ្មែរ, វៀតណាមខាងជើង និងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន ពិភាក្សាអំពីការទាមទាររបស់ខ្មែរ សុំឲ្យដកកងទ័ពបរទេសចេញពីស្រុកខ្មែរ ។ នៅថ្ងៃនោះផងដែរ ក៏មានបាតុកម្មបន្ថែមទៀតនៅទីក្រុងភ្នំពេញ ប្រឆាំងវៀតណាមខាងជើងនិងវៀតកុង ។ ថ្ងៃបន្ទាប់មក គឺថ្ងៃទី១៧មិនា, កងទ័ពពិសេសវៀតណាមខាងត្បូងបានចូលមកក្នុងទឹកដីខ្មែរចម្ងាយ១គីឡូម៉ែត្រកន្លះ ។

ថ្ងៃទី១៨មិនា, សីហនុបានត្រូវគេដកចេញពីតំណែងប្រមុខរដ្ឋ ដោយការបោះឆ្នោតជាឯកច្ឆន្ទនៃសភាខ្មែរ ។ ព្រះអង្គបានត្រូវគេទូលប្រាប់ឲ្យដឹងអំពីការដកហូតតំណែងនេះ នៅពេលព្រះអង្គកំពុងធ្វើដំណើរចាកចេញពីទីក្រុងម៉ូស្គូទៅកាន់ទីក្រុងប៉េកាំង ។ នៅសៃហ្គង, ប្រធានាធិបតីធីវ បានត្រូវកាសែតអាមេរិកាំងរាយការណ៍និយាយអំពីការកំចាត់ចេញពីតំណែងរបស់សីហនុយ៉ាងដូច្នេះថា ៖ «បើកម្ពុជា និងវៀតណាមខាងត្បូង ព្រមទាំងមានសហប្រតិបត្តិការពីសម្ព័ន្ធមិត្តនៅតាមបណ្តោយព្រំដែន, នោះខ្ញុំជឿថាពួកកុម្មុយនិស្តពុំអាចរកអ្វីស្ថិតនៅបានឡើយ» ។ ថ្ងៃទី១៩មិនា, អ្នកនាំពាក្យក្រសួងការបរទេសអាមេរិកាំងនិយាយថា ចម្លើយចំពោះសំនួរអំពី«ការទទួលស្គាល់»នោះ ពុំមានលើកឡើងឡើយ ទាក់ទងទៅនឹងរដ្ឋាភិបាលថ្មីរបស់ខ្មែរ ។

ថ្ងៃទី២០មិនា, មានការវាយប្រហារនៃយន្តហោះវៀតណាមនិងកងទ័ពថ្មើរជើង ឆ្លងកាត់ព្រំដែនខ្មែរ ។ ថ្ងៃទី២៣មិនា, រដ្ឋាភិបាលក្រុងប៉េកាំងបានចេញផ្សាយនូវសេចក្តីថ្លែងការណ៍មួយរបស់សីហនុ ដើម្បីប្រកាសឲ្យដឹងអំពីបំណងរបស់ព្រះអង្គ រៀបចំបង្កើតកងទ័ពរំដោះជាតិ ។ នៅថ្ងៃដដែលនោះ, នៅទីក្រុងភ្នំពេញ, វៀតណាមខាងជើងនិងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នបានប្រាប់ទៅរដ្ឋាភិបាលខ្មែរឲ្យដឹងថា ពួកគេមិនចូលរួមក្នុងកម្មវិធីជួបពិភាក្សាគ្នា អំពីការទាមទាររបស់ខ្មែរសុំដកកម្លាំងរបស់របស់ពួកគេទេ ។ ពួកគេបញ្ជាក់ថែមទៀតថា គ្មានការជជែកគ្នាជាផ្លូវការអំពីរឿងនេះទៀតឡើយ ។ ថ្ងៃទី២៣និង២៦មិនា, មានការបះបោរប្រឆាំងសីហនុ បានកើតឡើងនៅតាមខេត្តខ្លះ ។

ថ្ងៃទី២៧មិនា, កងឯកភាពរថក្រោះវៀតណាមខាងត្បូង ដោយមានការគាំទ្រពីកងកាំភ្លើងធំ និងការបាញ់ប្រហារពីអាកាសផង បានចូលមកក្នុងទឹកដីខ្មែរចម្ងាយប្រហែល១គីឡូម៉ែត្រកន្លះ ។ អ្នកនាំពាក្យកងទ័ពវៀតណាមខាងត្បូងនៅទីក្រុងព្រៃនគរបដិសេធការឆ្លងកាត់ព្រំដែននេះ, តែបើយោងតាមសេចក្តីរាយការណ៍ពត៌មានវិញ, ពួកមន្ត្រីអាមេរិកាំងនៅវ៉ាស៊ិនតោន បានត្រូវគេដកស្រង់ពាក្យសំដីនិយាយថា ការវាយប្រហារនោះបានធ្វើឡើងដោយគ្មានការដឹងឮនិងការយល់ព្រមពីខាងអាមេរិកាំងទេ ។ នៅក្នុងថ្ងៃដដែលនោះ, ពួកបុគ្គលិកភាគច្រើននៃស្ថានទូតវៀតណាមខាងជើងនិងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នប្រចាំនៅទីក្រុងភ្នំពេញ បានចាកចេញតាមយន្តហោះទៅកាន់ទីក្រុងហាណូយ ។

## ខែមេសា-ឧសភា

ប្រហែលនៅថ្ងៃទី១មេសា, វៀតណាមខាងជើងនិងវៀតកុងចាប់ផ្តើមធ្វើការវាយប្រហារប្រឆាំងប៉ុស្តិ៍ការពារខ្មែរនៅតាមព្រំដែន ដែលសកម្មភាពនេះបានត្រូវបកស្រាយនៅវ៉ាស៊ិនតោន និងដោយបញ្ជាការជំនួយយោធាអាមេរិកាំងនៅវៀតណាម (MACV) ថាគឺរៀបចំឡើងសំរាប់ជាការការពារត្រួតត្រាខ្សែក្រវាត់ ចាប់ពីតំបន់«ផ្លែសន្ទូច»ទៅដល់ឈូងសមុទ្រសៀម ។ ថ្ងៃទី២មេសា, រដ្ឋមន្ត្រី Rogersបានទៅបង្ហាញខ្លួននៅចំពោះមុខគណៈកម្មាធិការផ្នែកទំនាក់ទំនងការបរទេស នៅក្នុងអង្គប្រជុំចាត់ចែងកិច្ចការ ។ គេបានប្រទះឃើញសេចក្តីរាយការណ៍ពត៌មាននិយាយថា គណៈកម្មាធិការបានត្រូវគេនិយាយប្រាប់ឲ្យដឹងថា រដ្ឋាភិបាល«ពុំបានលើកទឹកចិត្ត»ឲ្យពួកវៀតណាមខាងត្បូងធ្វើប្រតិបត្តិការឆ្លងកាត់ព្រំដែនទេ រួចថែមទាំងបានព្រមានវៀតណាមខាងត្បូងយ៉ាងច្បាស់ថា សហរដ្ឋអាមេរិកចាត់ទុកការធ្វើប្រតិបត្តិការបែបនេះជា «ការមិនគួរត្រូវធ្វើទេ»នៅក្នុងដំណាក់កាលបច្ចុប្បន្ន ។ បីថ្ងៃក្រោយមក គឺនៅថ្ងៃទី៥មេសា, កងទ័ពវៀតណាមខាងត្បូងចំនួនពីរកងវរៈសេនាតូច បានឆ្លងចូលទៅក្នុងទឹកដីខ្មែរចម្ងាយ១០ម៉ែល៍ ។ អ្នកនាំពាក្យអាមេរិកាំងម្នាក់និយាយថា ប្រតិបត្តិការនោះគ្មានការគាំទ្រពីអាមេរិកាំងទេ ។

មកដល់ត្រង់ចំណុចនេះ, ពួកអាណិកជនប្រឆាំងចាប់ផ្តើមបះបោរនៅក្នុងស្រុកខ្មែរ ។ គួរបញ្ជាក់ថា នៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរចំនួន៧លានាក់ មានរួមពួកអាណិកជនជាតិយួននៅក្នុងនោះចំនួន៤០០,០០០នាក់ ដែលភាគច្រើនបានមករស់នៅក្នុងស្រុកខ្មែរពេញមួយជីវិតរបស់ពួកគេ ។ គេនិយាយថា ភាគច្រើននៃជនជាតិយួនទាំងអស់នេះ បើគេពិនិត្យមើលទៅ ចំនួនប្រហែល៧៥ភាគរយ បើយោងតាមសំដីពួកមន្ត្រីរដ្ឋាភិបាលខ្មែរនិងសូម្បីតែពួកមន្ត្រីវៀតណាមខាងត្បូងខ្លះបានអះអាងថា ចំនួនភាគរយត្រូវតែខ្ពស់ជាងនេះទៅទៀត គឺពួកអាណិកជនជាតិយួនទាំងអស់នោះសុទ្ធជាពួកគាំទ្រវៀតណាមខាងជើង ។ ថ្ងៃទី១៩មេសា, អាណិកជនជាតិយួនចំនួន៨៩នាក់ បានត្រូវគេសម្លាប់នៅប្រសូត ។ ពួកមន្ត្រីខ្មែរអះអាងថា ពួកនេះត្រូវគ្រាប់ស្លាប់នៅកណ្តាលការបាញ់ឆ្លងគ្នាទៅវិញទៅមក ក៏ប៉ុន្តែអ្នកកាសែតដែលស្ថិតនៅទីនោះនាពេលនោះដែរនិយាយថា ទាហានខ្មែរបានបាញ់រះទៅលើភូមិយ៉ាងចេតនា ។ នាថ្ងៃបន្ទាប់មក, ពួកជនជាតិយួនរស់នៅក្នុងទីក្រុងភ្នំពេញ បានត្រូវគេហាមឃាត់ធ្វើដំណើរចន្លោះចាប់ពីម៉ោង៦ល្ងាចដល់ម៉ោង៦ភ្លឺ ។

ក្នុងពេលជាមួយគ្នានេះ, វៀតណាមខាងត្បូងបានបន្តធ្វើប្រតិបត្តិការឆ្លងកាត់ព្រំដែនចូលទៅក្នុងស្រុកខ្មែរ ។ ថ្ងៃទី១២មេសា, កងកម្លាំងពិសេសវៀតណាមខាងត្បូងមួយកង បានចូលជ្រៅទៅក្នុងដីខ្មែរចម្ងាយប្រវែង៨គីឡូម៉ែត្រ រួចហើយបន្តធ្វើបែបនេះបួនថ្ងៃជាប់ៗគ្នា ។ ថ្ងៃទី១៤មេសាមានការធ្វើសហប្រតិបត្តិការរួមគ្នាជាលើកទី១ រវាងកងទ័ពវៀតណាមខាងត្បូងជាមួយកងទ័ពខ្មែរ បានត្រូវគេរាយការណ៍ឲ្យដឹង ។ នៅក្នុងពេលប្រហែលជាមួយគ្នានេះដែរ, កងទ័ពវៀតណាមខាងជើងបានចាប់ផ្តើមរុលឆ្ពោះទៅទិសខាងលិច ចេញពីតំបន់ចំពុះសេក ។ ចលនានេះបានបញ្ជាក់ឲ្យដឹងដោយរដ្ឋមន្ត្រី Laird កាលពីថ្ងៃទី១៤ឧសភា ពេលគាត់និយាយប្រាប់ទៅពួកអ្នកកាសែតថា កាលពីពាក់កណ្តាលខែមេសា កងទ័ពបច្ចាមិត្តបានចាប់ផ្តើមធ្វើចលនា «ទៅកាន់ទិសផ្សេងទៀតជាលើកទី១» ដែលគាត់ពោលបន្ថែមថា «ធ្វើឲ្យការប្រថុយប្រថានទៅលើកងទ័ពអាមេរិកាំងបានចុះយ៉ាងទាបជាទីបំផុត» ។

ថ្ងៃទី១៥មេសា, មានការប៉ាន់ស្មានសាកសពចំនួនប្រហែល១,០០០ ដែលគេនិយាយថាសុទ្ធតែជាពួកអាណិកជនជាតិយួន ត្រូវគេរាយការណ៍ឃើញអណ្តែតក្នុងទន្លេមេគង្គ ។ ថ្ងៃបន្ទាប់មក, មានអាណិកជនស៊ីវិលយួនចំនួនប្រហែល១០០នាក់បានត្រូវគេរាយការណ៍មកថា ត្រូវទាហានខ្មែរបាញ់សម្លាប់នៅខេត្តតាកែវ ។ ថ្ងៃទី១៧មេសា, អ្នកនាំពាក្យយោធាខ្មែរនិយាយថា វៀតណាមខាងជើងនិងវៀតកុងបានវាយកាន់កាប់ខេត្តចំនួន៣ក្នុងខេត្តខ្មែរទាំងអស់ចំនួន១៧ ព្រមទាំងត្រួតត្រាកាន់កាប់ជាងពាក់កណ្តាលនៃខេត្តចំនួនប្រាំផ្សេងទៀត ។ នៅថ្ងៃដដែលនោះ, កងកម្លាំងវៀតណាមខាងជើងនិងវៀតកុង បានវាយយកបានផ្សារស្នោង ស្ថិតនៅចម្ងាយ២០ម៉ែល៍ទិសខាងត្បូងក្រុងភ្នំពេញ ។ នៅរដ្ឋធានីវ៉ាស៊ិនតោន មានការប្រកាសឲ្យដឹងថា បានទទួលនូវការស្នើសុំអាវុធនិងឧបករណ៍យោធាជាពិសេស ពីកងទ័ពនៃរដ្ឋាភិបាលខ្មែរ ។

ថ្ងៃទី១៧មេសា, រដ្ឋមន្ត្រីការបរទេសវៀតណាមខាងត្បូងបានចេញផ្សាយនូវសេចក្តីថ្លែងការណ៍មួយ សំដែងឲ្យឃើញនូវចំណាប់អារម្មណ៍អំពីការថែរក្សាការពារពួកអាណិកជនភាគតិចជាតិយួនរស់នៅក្នុងប្រទេសកម្ពុជា ។ សេចក្តីថ្លែងការណ៍បង្ហាញឲ្យឃើញនូវកំហឹងពុះកញ្ជ្រោលនៅក្នុងស្រុកយួនអំពីរឿងនេះ ។

ថ្ងៃទី២០មេសា, កងទ័ពរថក្រោះនិងកងវរៈសេនាតូចថ្មើរជើងវៀតណាមខាងត្បូង បានបើកប្រតិបត្តិការពេលយប់នៅក្នុងតំបន់«ចំពុះសេក

» ។ នាថ្ងៃបន្ទាប់, កងកម្លាំងវៀតណាមខាងត្បូងបានចូលជ្រៅទៅដល់តំបន់មូលដ្ឋានមួយ ស្ថិតនៅក្នុងដីខ្មែរទល់មុខនឹងខេត្តចូវដុក ។ ក្នុងថ្ងៃជាមួយគ្នានោះ, រដ្ឋាភិបាលខ្មែរប្រាប់ឲ្យដឹងថា លន់-នល់បានធ្វើការអំពាវនាវក្នុងលិខិតផ្ទាល់ខ្លួនមួយច្បាប់ទៅប្រធានាធិបតីនិចសុន ដើម្បីសុំអាវុធពីអាមេរិកាំង និងសុំជំនួយពីកងកម្លាំងខ្មែរ ដែលគេធ្លាប់ស្គាល់ថាជាពួកអាណិកជនមានដើមកំណើតជាខ្មែរ កំពុងរស់នៅក្នុងប្រទេសវៀតណាមខាងត្បូង និងដែលកំពុងបំរើការជាក្រុមការពារជនស៊ីវិលមិនប្រក្រតី (ភាសាអង់គ្លេសហៅថា Civilian Irregular Defense Group - CIDG) ធ្វើការក្នុងកងកម្លាំងពិសេសអាមេរិកាំង (កកន ៖ ឬគេហៅថា កងទ័ពម៉ែកហ្វ័ស) ឲ្យចុះទៅជួយក្នុងស្រុកខ្មែរ ។

ថ្ងៃទី២០មេសា, ប្រធានាធិបតីនិចសុន, នៅក្នុងសេចក្តីប្រកាសដកកងទ័ពអាមេរិកាំងនាពេលអនាគតចេញពីវៀតណាម បានលើកឡើងអំពី «ការកើនឡើងនៃបច្ចាមិត្តនៅក្នុងប្រទេសលាវនិងកម្ពុជា» ដោយថ្លែងបញ្ជាក់ថា ពួកបច្ចាមិត្តមុខជា«ធ្វើការប្រថុយប្រថានវាយប្រហារយ៉ាងធំ» ដោយប្រើប្រាស់ការដកកងទ័ពអាមេរិកាំងចេញពីវៀតណាម ធ្វើទៅលើកងទ័ពអាមេរិកាំងដែលនៅសេសសល់ក្នុងវៀតណាម រួចហើយនឹងបង្កើនសកម្មភាពយោធាកាន់តែខ្លាំងនៅវៀតណាម, នៅកម្ពុជា និងនៅប្រទេសលាវ ។ និចសុននិយាយថា បើពួកគេធ្វើដូច្នេះមែន «ខ្ញុំមិនរួញរាអ្វីប្រើចាត់វិធានការយ៉ាងខ្លាំងក្លានិងមានប្រសិទ្ធិភាព ដើម្បីទប់ទល់នឹងស្ថានភាពនេះឡើយ» ។

ថ្ងៃទី២២មេសា, រដ្ឋាភិបាលបើកបង្ហាញឲ្យឃើញនៅវ៉ាស៊ិនតោនថា អាវុធដែលរឹបអូសយកបាន នឹងប្រគល់ទៅឲ្យខ្មែរ ។ ថ្ងៃបន្ទាប់មក, គេក៏បានប្រកាសឲ្យដឹងទៀតថា កប៉ាល់ទី១បានដឹកអាវុធទៅដល់ទីក្រុងភ្នំពេញ ដោយវៀតណាមខាងត្បូង តាមការដឹងឮនិងការយល់ព្រមពីអាមេរិកាំង ។ ក្នុងថ្ងៃដដែលនោះ, «សន្និសិទនៃប្រជាជនឥណ្ឌូចិន»បានចាប់ផ្តើមធ្វើនៅខេត្តខាងត្បូងនៃប្រទេសចិន ។ សន្និសិទមានរយៈពេលពីរថ្ងៃ ដោយមានការចូលរួមពីផាំ-យ៉ាំងដុង នាយករដ្ឋមន្ត្រីវៀតណាមខាងជើង, ង្វៀង-ហ៊ុយថូ នៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន , ទ្រង់សុផានុវង្ស ប្រធានាធិបតីរណសិរ្សស្នេហាជាតិលាវ, ទ្រង់សីហនុ, រួចហើយនៅថ្ងៃចុងក្រោយ មានការចូលរួមពីជូ-អេនឡាយ នាយករដ្ឋមន្ត្រីចិនផង ។

ថ្ងៃទី២៤មេសា, អ្នកនាំពាក្យសេតវិមានបានថ្លែងថា ការវាយលុកនៃវៀតណាមខាងជើងនិងវៀតកុងនៅក្នុងប្រទេសកម្ពុជា «គឺជាកាឈ្លានពាននៃបរទេសទៅលើអព្យាក្រឹត្យភាពនៃប្រទេសនេះ ដែលពុំអាចចាត់ទុកតាមបែបផែនណា ថាជាសង្គ្រាមស៊ីវិលបានឡើយ» ។

ថ្ងៃទី២៧មេសា, រដ្ឋមន្ត្រី Rogers បានធ្វើការបំភ្លឺសារជាថ្មី នៅមុខគណៈកម្មាធិការផ្នែកទំនាក់ទំនងការបរទេស ក្នុងពេលប្រជុំចាត់ចែងកិច្ចការ ។ សេចក្តីរាយការណ៍ពត៌មានពេលយប់ទៅហើយនិយាយថា លោករដ្ឋមន្ត្រីថា មានការវាយលុកទន្ទ្រានចូលទៅក្នុងទឹកដីខ្មែរមួយចំនួនធ្វើឡើងដោយកងកម្លាំងវៀតណាមខាងត្បូង ជាប្រតិបត្តិបានទទួលនូវជោគជ័យយ៉ាងគួរឲ្យពេញចិត្ត ។ លោកនិយាយថា ការកាន់កាប់របស់ពួកកុម្មុយនិស្តនៅក្នុងស្រុកខ្មែរ គឺបង្កើននូវឧប្បទ្រពចង្រៃដល់នយោបាយរបស់អាមេរិកាំង ក្នុងការដកកងទ័ពចេញពីវៀតណាម ។ ក្នុងថ្ងៃជាមួយគ្នានោះ, អ្នកនាំពាក្យសេតវិមានបានត្រូវគេដកស្រង់ពាក្យសំដីនិយាយថា សហរដ្ឋអាមេរិកពុំចង់បាននូវ «អត្ថប្រយោជន៍អ្វីលើសលប់» នៅក្នុងស្រុកខ្មែរ អំពី«ថាតើលទ្ធភាពនៃពួកកុម្មុយនិស្តអាចយកស្រុកខ្មែរបាននឹងមានការប៉ះទង្គិចទៅដល់កម្លាំងរបស់យើងនៅវៀតណាម ហើយនិងកម្មវិធីវៀតណាមូបនិយកម្ម»នោះទេ ។ ថ្ងៃទី២៩មេសា, ប្រតិបត្តិការមានឈ្មោះថា «អ្នកបំបែកថ្ម» ជាប្រតិបត្តិការរបស់វៀតណាមខាងត្បូង ដោយមានជំនួយពីទីប្រឹក្សាអាមេរិកាំង និងដោយមានការគាំទ្រផ្នែកយុទ្ធសាស្ត្រពីកងទ័ពអាកាសអាមេរិកាំងផង បានធ្វើនៅតំបន់«ចំពុះសេក» ។

ថ្ងៃទី៣០មេសា (ថ្ងៃទី១ឧសភានៅវៀតណាម), លោកប្រធានាធិបតីបានប្រកាសឲ្យដឹងថា កម្លាំងសហរដ្ឋអាមេរិក «ក្នុងសហប្រតិបត្តិការជាមួយកម្លាំងទ័ពវៀតណាមខាងត្បូង» បានបើកប្រតិបត្តិក្នុងសប្តាហ៍នេះ « ដើម្បីធ្វើការបោសសំអាតជំរកយ៉ាងសំខាន់របស់បច្ចាមិត្ត ស្ថិតនៅត្រង់ព្រំដែនខ្មែរ-យួន» ។ លោកនិយាយថា «បច្ចាមិត្ត, នៅក្នុងរយៈពេលពីរសប្តាហ៍កន្លងមកនេះ បានបង្កើនសកម្មភាពទ័ពព្រៃយ៉ាងខ្លាំងក្លា ។ ពួកគេផ្តោតគំនិតតែទៅលើកម្លាំងយ៉ាងសំខាន់នៅក្នុងជំរក ដែលជាទីកន្លែងពួកគេកទ័ពសំរាប់បើកការវាយប្រហារយ៉ាងធំ មកលើកម្លាំងរបស់យើងនិងរបស់វៀតណាមខាងត្បូង» ។ លោកបានប្រកាសឲ្យដឹងថា កងឯកភាពសហរដ្ឋអាមេរិកនិងវៀតណាមខាងត្បូង នឹងធ្វើប្រតិបត្តិការរួមគ្នាក្នុងពេលឆាប់ៗនេះ បើក«វាយប្រហារទៅលើបញ្ជាការដ្ឋានសំរាប់ប្រតិបត្តិការពួកកុម្មុយនិស្តទាំងមូលនៅវៀតណាមខាងត្បូង» ។ លោកបានថ្លែងថា ការវាយប្រហារនេះ«ពុំមែនជាអំពើឈ្លានពានកម្ពុជាទេ» ពីព្រោះនៅត្រង់ទីកន្លែងនោះគឺជា «តំបន់ដែលការវាយប្រហារនានាកើតចេញមក និងជាតំបន់ត្រួតត្រានៅក្រោមកម្លាំងទ័ពវៀតណាមខាងជើង» ។ រួចហើយលោកនិយាយថា ការវាយប្រហារទៅលើជំរកនេះ «គឺជាការវាយប្រហារពុំអាចចៀសវាងបាន ដើម្បីបន្តជ័យជំនះ» ទៅលើកម្មវិធីដកកម្លាំងអាមេរិកាំងចេញពីវៀតណាម ដែលជា«កិច្ចការដ៏សំខាន់ខ្លាំងណាស់» សំរាប់រក្សាឲ្យការខូចខាតរបស់អាមេរិកាំង ស្ថិតនៅយ៉ាងទាបជាទីបំផុត ព្រមទាំងសំរាប់បំរើនូវវត្ថុបំណង «ធ្វើការបញ្ចប់សង្គ្រាមនៅវៀតណាម និងជ័យជំនះដែលយើងទាំងអស់គ្នាចង់បាន» នោះផងដែរ ។

ថ្ងៃទី៥ឧសភា, សីហនុបានប្រកាសឲ្យដឹងនៅទីក្រុងប៉េកាំង អំពីការរៀបចំបង្កើតរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ ។ រាជរដ្ឋាភិបាលបានត្រូវទទួលស្គាល់ដោយចិនកុម្មុយនិស្តក្នុងថ្ងៃនេះ និងបានត្រូវទទួលស្គាល់ដោយវៀតណាមខាងជើងនិងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននាថ្ងៃជាបន្ទាប់មក ។

( នៅមានត )

( កកន ៖ បងប្អូនរួមឈាមជាទីស្នេហា, ដូចខ្ញុំ (លី-ឡៅ) បានលើកឡើងជាញឹកញាប់រួចមកហើយ អំពីមូលហេតុវិនាសកម្មខ្មែរបច្ចុប្បន្ននេះ ។ ឯកសារប្រវត្តិសាស្ត្រភាគច្រើនចង្អុលបង្ហាញឲ្យយើងបានឃើញថា ស្តេចសីហនុ គឺជាប្រភពតែមួយគត់នៃវិបត្តិ ។ ពួកមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ ក្រៅអំពី«ទទួលថ្នូបាក់»ពីស្តេចសីហនុហើយ ត្រូវស្តេចសីហនុរិះគន់វាយប្រហារគ្មានឈប់ឈរទៀត សូម្បីពួកគេស្លាប់ជាខ្មោចទៅហើយយ៉ាងណាក្តី ។

បើយើងពិនិត្យក្រឡេកបកមើលទៅក្រោយវិញ យើងពុំឃើញពួកមេដឹកនាំសាធារណរដ្ឋខ្មែរទាំងអស់នោះ ប្រព្រឹត្តអំពើ«ក្បត់ជាតិ»អ្វីសោះ ក្រៅអំពីការពារអធិបតេយ្យភាព ឯករាជភាព និងបូរណភាពទឹកដីរបស់ស្រុកយើង ពីពួកសត្រូវយួនឈ្លានពានប៉ុណ្ណោះ ។ ធ្វើដូច្នេះ តើខុសអ្វីទៅ ? ។ ខ្ញុំបានមើលឃើញថា នៅពេលដែលស្តេចសីហនុត្រូវពលរដ្ឋខ្មែរដង្ហែរចុះពីតំណែង«ប្រមុខរដ្ឋ» ឲ្យទៅ«ទ៊ីត្រែត»នៅស្រុកបារាំងឬស្រុកចិននាពេលនោះ បើព្រះអង្គមិនធ្វើ«សកម្មភាពនយោបាយ»អ្វីទេ ស្រុកយើងពិតជាពុំធំក្លិនឆ្អាបឈាមបងប្អូនរួមជាតិយើងយ៉ាងដូច្នេះឡើយ ។ ដោយសារមហិច្ឆតាផ្ទាល់ខ្លួន, ស្តេចសីហនុបានហក់ទៅចូលដៃជាមួយសត្រូវសួរជាតិ ធ្វើឲ្យពួកអស់នេះមាន«លេស»បើកការវាយប្រហារកាប់សម្លាប់មកលើប្រជាពលរដ្ឋខ្មែរស្ទើរពោយអស់ពីនគរ ។

ព្រឹត្តិការណ៍ផ្សេងៗកើតឡើងជាបន្តបន្ទាប់គ្នា វាគ្មានអ្វីក្រៅអំពីកំស្ទួលនៃ
សង្គ្រាមប៉ុណ្ណោះ ៖ បាតុកម្មបះបោរ, ការបាញ់សម្លាប់បាតុករ, ការសម្លាប់
ពួកអាណិកជនជាតិយួន ។ល។ និង ។ល។ វាជាឧប្បត្តិហេតុដែលគ្មាន
នរណាមួយអាចដឹងជាមុនបានទេ ។ អំពើពុករលួយ ដែលខ្ញុំតែងបានឮ
ពីសំណាក់មិត្តអ្នកអានខ្លះ... ថាវាជា«កត្តា»បរាជ័យមួយយ៉ាងធំនៃរប
បសាធារណរដ្ឋខ្មែរនោះ ខ្ញុំពុំដែលបានចៀសវាងមិនព្រមទទួលយកម្តង
ណានោះទេ ក៏ប៉ុន្តែគួរយើងធ្វើការពិចារណាត្រិះរិះអំពីសង្គមមួយ ដែល
កំពុងស្ថិតនៅកណ្តាលភ្លើងសង្គ្រាម ។ ហើយសង្គ្រាមនេះទៀតសោត
របបសាធារណរដ្ឋខ្មែរដ៏«ក្មេងខ្ចី» ប្រដូចទៅនឹងទារកទើបនឹងកើត ត្រូវ
ចេញមុខទប់ទល់ជាមួយ«សត្រូវ»ប្រកបដោយបទពិសោធន៍ក្នុងសង្គ្រា
មរាប់សិបឆ្នាំ, មានកម្លាំងទ័ពយ៉ាងខ្លាំងក្លា, មានអាវុធយុទ្ធភ័ណ្ឌដ៏ទំនើប
និងដ៏សំបើម..ជាពិសេសយើងមានសត្រូវផ្ទៃក្នុងខ្មែរក្រហមថែមទៀត។
បន្ថែមពីលើនេះ, មន្ត្រីនិងនាយទាហានពួកសីហានុនិយមជាច្រើន ត្រូវបា
នទទួលនូវការមេត្តាករុណាពីថ្នាក់ដឹកនាំរបបសាធារណរដ្ឋខ្មែរ ឲ្យបន្តការ
ងាររបស់ខ្លួនជាធម្មតា ដោយគ្មានយកទោសពៃរ៍អ្វីឡើយ ។ វិទ្ធង្សនាលើ
ផ្នែកសេដ្ឋកិច្ច, អសន្តិសុខផ្ទៃក្នុង, ការជន្លៀសគ្រួសារដើម្បីរត់ទៅរកកន្លែ
ងសុខ, វិនាសកម្មអាយុជីវិតនិងទ្រព្យសម្បត្តិ, ការមិនអាចចេញទៅប្រក
បរបររកស៊ីជាធម្មតាបាន... ជាពិសេសការពុំអាចគ្រប់គ្រងលើស្ថានការ
ណ៍ស្រុកទាំងមូល... ជាហេតុបច្ច័យធ្វើឲ្យអំពើពុករលួយពាសវាលពាស
កាល ។ បើយើងប្រៀបធៀបសម័យសាធារណរដ្ឋខ្មែរនៅក្នុងភ្លើងស-
ង្គ្រាម មកសម័យរាជាណាចក្រទី២ក្នុងសន្តិភាពនេះ យើងអាចរកឃើញ
ថា មានកំរិតពុករលួយខុសគ្នាដូចមេឃនិងដី ។ ខ្លួនខ្ញុំផ្ទាល់កម្រប្រទះ
ឃើញមាននាយទាហានជំនាន់សាធារណរដ្ឋខ្មែរណាម្នាក់ ដែលមានស
ម្បត្តិហូរហៀដូចពួកមន្ត្រីខ្មែរបច្ចុប្បន្ននេះទេ ភាគច្រើនឃើញតែរស់នៅ
មួយគែរៗជាមួយនិងគ្រួសារយ៉ាងស្វាត់ស្ងៀមបំផុត ។ ប្រទេសណាក៏
ដោយ បើកាលណាមានសង្គ្រាមហើយ កុំសូម្បីទប់ស្កាត់អំពើពុករលួយ
តែអាយុជីវិតនៃប្រជាពលរដ្ឋក៏ពុំអាចធានាបានឡើយ ។ ការបាត់បង់នូវ
ភាពគ្រប់គ្រង ត្រូវតែជារឿងស្វ័យប្រវត្តិ។ ខ្ញុំមិនដែលបានដឹងថា តើមាន
ប្រទេសណាមួយនៅក្នុងពិភពលោកនេះ ដែលធ្លាក់ទៅក្នុងភ្លើងសង្គ្រាម
ហើយ ៗអាចទប់ទល់អំពើពុករលួយ និងគ្រប់គ្រងស្ថានការណ៍ស្រុកទេ
សទាំងមូលបានទេ ? ។ ដូច្នេះ«បរាជ័យ»នៃរបបសាធារណរដ្ឋខ្មែរ ពុំមែ
នមកពីអំពើពុករលួយនេះតែមួយនោះទេ គឺមានកត្តានយោបាយធំៗដទៃ
ផ្សេងទៀត ជាពិសេសការផ្លាស់ប្តូរនយោបាយសហរដ្ឋអាមេរិក ។

បែរមកស្តេចសីហានុវិញ, ខ្ញុំតែងឮព្រះអង្គមានបន្ទូលអំពី«កងទ័ពរំដោះ»
ដែលព្រះអង្គអះអាងថា ព្រះអង្គជាអ្នកបង្កើតឡើងក្នុងស្រុកខ្មែរ កាលពី
អំឡុងដើមឆ្នាំ៧០ ។ ខ្ញុំឮសួរតែដូច្នេះ ក៏ប៉ុន្តែពុំឃើញមានឯកសារអ្វីមួយ
ច្បាស់លាស់កត់ត្រាអំពីផ្នែកនេះសោះ ។ ខ្ញុំបានចោទជាសំនួរច្រើនដងរួ
ចមកហើយចំពោះស្តេចសីហានុ និងពួករាជានិយមឆ្កើមៗខ្លះ អំពីទីតាំង
នៃកងទ័ព ចំនួនពលទាហាន និងឈ្មោះនៃពួកមេបញ្ជាខ្លះក្នុងសមរភូមិ
ទាំងអស់នោះ ។ ខ្ញុំចង់ឃើញឯកសារនេះ តែរហូតមកដល់ថ្មីណេះ ខ្ញុំ
មិនទាន់បានឃើញនិងបានទទួលនៅឡើយ ។ ផ្ទុយទៅវិញ, អ្វីដែលខ្ញុំបា
នដឹងនោះគឺគ្មានអ្វីក្រៅអំពីកងទ័ពដែលពួកយួនហៅថាជា «កងទ័ពរំដោះ
ខ្មែរ» ដែលពួកវាជាអ្នកបំពាក់អាវុធបំពាក់ស្មារតីឲ្យ ។ «កងទ័ពរំដោះ»
នេះដល់ថ្ងៃក្រោយមក គឺជាកងទ័ពខ្មែរក្រហមដ៏ឃោរឃៅព្រៃផ្សៃ ដែល
មានមុខព្រួញសំរាប់កាប់សម្លាប់ប្រហារជីវិតខ្មែរទូទៅ ។ ថ្ងៃទី១៧ មេសា
១៩៧៥, កងទ័ពដែលស្តេចសីហានុបានហៅថា «កងទ័ពរំដោះ» បានទទួ
លជោគជ័យលើរបបសាធារណរដ្ឋខ្មែរ ។ ពួកគេបាននាំគ្នាទៅដង្ហែរមេ
ដឹកនាំរបស់ពួកគេពីវាំងក្រុងប៉េកាំង ឲ្យមកទទួលនាទីជា «ប្រធានាធិបតី
កម្ពុជាប្រជាធិបតេយ្យ» នៅទន្ទឹមពេលពួកគេគាស់ក្រឡាប់ផែនដីស្រុក
ខ្មែរទាំងមូល ធ្វើជា«លានពិឃាត»ពិភពលោកនៃសតវត្សទី២០ ។៚

<u>បញ្ជាក់បន្ថែម</u> ៖ នៅក្នុងការចុះផ្សាយ «អត្ថបទឯកសារប្រវត្តិសាស្ត្រ» ក៏
ដូចគ្នានិងអត្ថបទផ្សេងៗដទៃទៀតដែរ, ខ្ញុំ (លី-ឡៀប) ពុំមានគំនិតថា ច
ង់អួតអាង ឬចង់បង្ហាញអំពីចំណេះដឹងអ្វី ដើម្បីលើកកំពស់ខ្លួនឯង ឬមួ
យសំរាប់មុខមាត់អ្វីនោះទេ ។ អត្ថបទទាំងអស់នេះ គឺសំរាប់ទុកជាឯក-
សារ ឬជាការបញ្ចេញមតិជាសាធារណៈតាមបែបផែនប្រជាធិបតេយ្យនិ
យម ដែលសារពត៌មាននានា«ត្រូវធ្វើ»ប៉ុណ្ណោះ ។ វាជាការពិតហើយ ដែ
លទស្សនៈរបស់«អង្គរបុរី» ភាគច្រើនជាទស្សនៈរបស់«ក្រុមស្នាំនិយម»
តែទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំក៏គ្មានសេចក្តីប្រាថ្នាអ្វីក្រៅអំពីបំរើ
ផលប្រយោជន៍ខ្មែរ និងមាតុភូមិកម្ពុជាដ៏ជាទីស្នេហានោះឡើយ ។ ជាមួ
យគ្នានេះផងដែរ ខ្ញុំសូមបញ្ជាក់ថា អត្ថបទទាំងអស់នេះ ខ្ញុំក៏បានលើកយ
កទៅចុះផ្សាយនៅលើទំព័រសារពត៌មាន«អង្គរបុរី» (Hard copy) សំរាប់
ចែកជូនដល់មិត្តអ្នកអានខ្មែររាប់ម៉ឺននាក់នៅគ្រប់ទិសទី ។ ខ្ញុំសូមឆ្លៀតឱ
កាសនេះ សំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការជួយ
គាំទ្រនិងការលើកទឹកចិត្ត ពីបងប្អូនរួមជាតិគ្រប់ទិសទី ដែលធ្វើឲ្យ«អង្គរ
បុរី» មានអាយុយឺតយូររហូតមកទល់សព្វថ្ងៃនេះ ។ សូមអរគុណ (!!)

ទស្សនាវដ្តី
សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ

## ប្រទេសកម្ពុជា
## ខែឧសភា ឆ្នាំ១៩៧០

### សេចក្តីរាយការណ៍រៀបចំឡើងដោយបុគ្គលិក សំរាប់ការប្រើប្រាស់នៃគណៈកម្មាធិការព្រឹទ្ធសភា ផ្នែកទំនាក់ទំនងការបរទេសសហរដ្ឋអាមេរិក

(បោះពុម្ពផ្សាយនៅថ្ងៃទី៧ មិថុនា ឆ្នាំ១៩៧០)

(បកប្រែក្រៅផ្លូវការ)

តមកពីលេខមុន...

## ទស្សនៈពីរដ្ឋាភិបាលក្រុងសៃហ្គន

នៅក្នុងទស្សនៈនៃជនភាគច្រើនដែលយើងបានជួប ក្នុងរយៈពេលធ្វើដំណើររបស់យើងទៅវៀតណាមខាងជើងនិងទៅវៀតណាមខាងត្បូងនោះ ការធ្លាក់ពីអំណាចរបស់សីហនុបានបង្កើតឲ្យមាននូវការគំរាម ដែលស្ទើរតែបង្ហាញឲ្យឃើញភ្លាមៗ ដោយការធ្វើបាតុកម្មប្រឆាំងវៀតណាមខាងជើងរៀបចំឡើងដោយរដ្ឋាភិបាលខ្មែរ, ឱសានវាទរបស់លន់-នល់ ហើយនិងវិធីប្រឆាំងចំពោះពួកអាណិកជនជាតិយួនរស់នៅក្នុងប្រទេសកម្ពុជា ។ ពួកវៀតណាមខាងជើងគិតថា ការវិវត្តន៍នៃព្រឹត្តិការណ៍នេះប្រហែលមានន័យថា ជំរករបស់ខ្លួនទាំងអស់នោះត្រូវលែងចាត់ទុកជាការរំលោភបំពានទៀតហើយ ។ ពីព្រោះអីវៀតណាមខាងត្បូងបានចាប់ផ្តើមពង្រីកទំហំប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយដែលមានក្នុងករណីខ្លះនោះ រួមដៃគ្នាជាមួយកម្លាំងកងទ័ពខ្មែរចាប់តាំងពីមុនការធ្លាក់ពីអំណាចនៃសីហនុទៀតផង ។

តាមឯកសារចាប់បានខ្លះ ដែលគេបានលើកយកមករាយការណ៍នៅក្រុងសៃហ្គងបង្ហាញឲ្យឃើញថា វៀតណាមខាងជើងនិងវៀតកុងបានរំពឹងគិតថា សហរដ្ឋអាមេរិកនិងវៀតណាមខាងត្បូង នឹងវាយសំរុកចូលទៅក្នុងជំរកដោយប្រើកម្លាំងវាយសន្ធប់យ៉ាងខ្លាំងក្លា។ ឯកសារផ្សេងទៀតដែលយើងបានដឹង គាំទ្រនូវគំនិតថា ពួកបច្ចាមិត្តរំពឹងគិតថាសហរដ្ឋអាមេរិក នឹងផ្តល់នូវការគាំទ្រមិនចំពោះ ដល់រដ្ឋាភិបាលលន់-នល់ និងក៏ពុំមានការធ្វើអន្តរាគមន៍ផ្ទាល់ពីសហរដ្ឋអាមេរិកដែរ ។ នៅមានឯកសារខ្លះទៀតនិយាយថា ក្នុងពេលថ្មីៗនេះ ក្រុងវ៉ាស៊ិនតោនបញ្ជាក់កម្លាំងបច្ចាមិត្តកំពុងប្រមូលផ្តុំគ្នានៅក្នុងជំរកក្នុងខែមេសាដើម្បីបើកការវាយប្រហារមកលើកម្លាំងសម្ព័ន្ធមិត្តនៅវៀតណាមខាងត្បូង ទោះបីយើងគ្មានបានឮសួរគេនិយាយអ្វីសោះអំពីឯកសារនេះនៅក្រុងសៃហ្គងក៏ដោយ ។ បើតាមមើលទៅឃើញហាក់ដូចជា ឯកសារដែលគេចាប់យកបាននោះ គឺសំរាប់តែដើម្បីតែគាំទ្រនូវអ្វីមួយដែលគេសរុបចង់ធ្វើប៉ុណ្ណោះ ។

ដោយគ្មានគិតអំពី ថាតើកម្លាំងរបស់បច្ចាមិត្តប្រើប្រាស់ឯកសាររបស់ខ្លួនណាមួយនោះ, យើងបានត្រូវអាជ្ញាធរយោធាសហរដ្ឋអាមេរិកនៅក្រុងសៃហ្គងនិយាយប្រាប់ថា ក្រោយពេលសីហនុត្រូវគេទម្លាក់ វៀតណាមខាងជើងបានផ្លាស់ប្តូរជំហរ ទៅសភាពទប់ទល់វិញនៅក្នុងទីជំរករបស់ពួកគេ ហើយក្នុងពេលមួយរំពេជបន្ទាប់មក ពួកគេចាប់ផ្តើមបំបែកទ័ពសំដៅទៅទិសខាងលិចចូលទៅក្នុងប្រទេសកម្ពុជា ។ មានការផ្តល់នូវការពន្យល់ផ្សេងៗ អំពីចលនារបស់បច្ចាមិត្តនេះ ។ ពួកមន្ត្រីសហរដ្ឋអាមេរិកខ្លះថ្លែងថា ពួកបច្ចាមិត្តកំពុងឆ្លៀតឱកាសឆក់យកប្រៀប លើការបង្ហាញឲ្យឃើញដោយរដ្ឋាភិបាលថ្មីនៅភ្នំពេញ ដែលបានចាត់ទុកពួកគេជាសត្រូវ និងឆ្ពោះទៅរកអ្វីដែលពួកគេអាក់ខានពុំបានធ្វើរហូតមកទល់ពេលនេះ គឺការ«ធ្វើឲ្យកាន់តែខ្លាប់»ថែមទៀត នូវខ្សែមូលដ្ឋានរបស់ពួកគេនៅក្នុងស្រុកខ្មែរ ហើយនិងផ្តល់ឲ្យពួកគេនូវទីធំទៀតសំរាប់ធ្វើការ ។ ពួកអ្នកផ្សេងទៀតមើលឃើញថា ការពង្រាយទ័ពនេះ គឺនៅក្នុងលក្ខណៈសំរាប់តែធ្វើការទប់ទល់ប៉ុណ្ណោះ ។ ហើយក៏នៅមានពួកខ្លះទៀតនោះ ប្រហែលចាត់ទុកថា ចលនាទ័ពនេះជាពិសេសកាលពីចុងខែមេសា គឺគេរៀបចំឡើង សំរាប់តែបង្កើនគំនាបទៅលើរដ្ឋាភិបាលលន់-នល់ ដើម្បីបង្ខំឲ្យធ្វើការសំរុះសំរួល បើមិនដូច្នោះទេនឹងត្រូវរលំដួលពុំខាន ។ គ្មានមន្ត្រីសហរដ្ឋអាមេរិកណាម្នាក់បានលើកឡើងនូវលទ្ធភាពដែលថា ទង្វើនៃរដ្ឋាភិបាលលន់-នល់ ហើយនិងការពង្រីកប្រតិបត្តិការឆ្លងកាត់ព្រំដែនចូលទៅក្នុងទឹកដីខ្មែរនៃកងម្លាំងវៀតណាមខាងត្បូង ក្រោយពេលការធ្លាក់ពីអំណាចនៃសីហនុ ប្រហែលបង្កឲ្យបច្ចាមិត្តរុលទៅទិសខាងលិចនោះទេ ។

ពីការពិភាក្សាគ្នារបស់យើងនៅក្រុងសៃហ្គង, ធ្វើឲ្យយើងប្រមើមើលឃើញថា កងទ័ពសហរដ្ឋអាមេរិកនិងវៀតណាមខាងត្បូង ចាត់ទុកការធ្លាក់ពីអំណាចរបស់សីហនុ គឺជា«ឱកាសមួយ»សំរាប់ធ្វើការវាយប្រហារទៅលើជំរកបច្ចាមិត្តនៅតាមបណ្តោយព្រំដែន ។ តាមពិត, ពួកមន្ត្រីយោធាសហរដ្ឋអាមេរិកនៅវៀតណាម បានប្រើពាក្យនេះយ៉ាងប្រាកដណាស់ រួចនិយាយថាបើប្រសិនគ្មានជំរកទាំងអស់នេះទេ សង្គ្រាមត្រូវចប់ពីយូរមកហើយ ។ មិនតែប៉ុណ្ណោះ, ឃ្លាមួយនេះហ្នឹងបានលេចឮហើយលេចឮទៀត នៅក្នុងពេលប្រជុំរាយការណ៍នៃបញ្ជាការជំនួយយោធានៅវៀតណាម (MACV) និងនៅក្នុងពេលសន្ទនាគ្នាជាមួយពួកមន្ត្រីអាមេរិកាំងដែលគេបន្ទរថា ៖ «គ្មានសង្គ្រាមទ័ពព្រៃណាមួយក្នុងប្រវត្តិសាស្ត្រនេះ ដែលអត់មានជំរកនោះបានទេ» ។ ការជាប់ទាក់ទងគ្នានោះគឺថា បើសង្គ្រាមទ័ពព្រៃគ្មានជំរកទេ សង្គ្រាមទ័ពព្រៃនោះពុំអាចយកជ័យជំនះបានឡើយ ។ ក៏ប៉ុន្តែគេគ្មាននិយាយថា ការធ្វើជំរកនៅតែមិនប៉ះពាល់ធ្វើឲ្យខូចខាតអ្វីនៅទិសខាងជើងនៃតំបន់អត់ទ័ព (DMZ) នោះឡើយ ។

❑

ការមើលឃើញពីសៃហ្គង បានធ្វើឲ្យមានគំនិតជំរុញប្លែកៗគ្នា អំពីការចូលទៅក្នុងប្រទេសកម្ពុជា ។ ពួកមន្ត្រីអាមេរិកាំងនិងវៀតណាមបានថ្លែងឲ្យដឹងនៅក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការមួយថា ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា គឺរៀបចំឡើងដើម្បីស្កាត់ចាប់យកស្បៀង, កាត់ផ្តាច់ខ្សែទាក់ទងគ្នា ហើយនិងបំផ្លាញទីបញ្ជាការរបស់ពួកវៀតកុង សំរាប់ជាការពន្យឺតពេលវេលាការធ្វើវៀតណាមូបនិយកម្ម និងសំរាប់កាត់បន្ថយសក្តានុពលនៃការធ្វើសង្គ្រាមនៅខាងវៀតណាមខាងត្បូង ដោយវិធីធ្វើឲ្យខូចខាតគ្រឿងសព្វាវុធរបស់ពួកវា ព្រមទាំងរុញច្រានពួកវាឆ្ពោះទៅទិសខាងលិច។ ពេលរដូវភ្លៀងធ្លាក់ជិតមកដល់នេះ គឺជាពេលបង្អួចបង្អាក់នៃការផ្តល់ស្បៀងឡើងវិញរបស់សត្រូវក៏ត្រូវបានគេលើកឡើងផងដែរ

ថាជាមូលហេតុបន្ថែម នៃការបើកការវាយប្រហារនាពេលនោះ ។ ពួកមន្ត្រីអាមេរិកាំងនិយាយផងដែរ អំពីសេចក្តីត្រូវការកាត់បន្ថយគំនាបសង្កត់របស់បច្ចាមិត្តទៅលើប្រទេសកម្ពុជា ពេលដែលវៀតណាមខាងត្បូងចង់សំដៅទៅលើ«ទិសដៅ» នៃការ«គាំទ្រប្រទេសជាមិត្តប្រឆាំងនឹងអំពើឈ្លានពានរបស់ពួកកុម្មុយនិស្ត» ។

ភាពយកចិត្តទុកដាក់នៃយួនខាងត្បូងចំពោះខ្មែរបែបនេះ វាពិតមែនហើយ ថាជាបាតុភូតដ៏អស្ចារ្យនាកើតឡើងថ្មីៗ ។ ភាគច្រើននៃជនដែលយើងបានជួបនិយាយជាមួយនៅសៃហ្គងអធិប្បាយថា អាកប្បកិរិយារបស់យួនចំពោះជនជាតិខ្មែរ គឺជាការបញ្ឆោរ បើពុំមែនចាត់ទុកជាអំពើមើលងាយទេ ។ តាមពិតទៅ, សេចក្តីរាយការណ៍ស្តីអំពីអំពើព្រៃផ្សៃប្រឆាំងអាណិកជនជាតិយួននៅក្នុងស្រុកខ្មែរ បានធ្វើឲ្យមានប្រតិកម្មយ៉ាងខ្លាំងជាពិសេសនៅក្នុងទីក្រុងសៃហ្គង ជាកន្លែងដែលពួកនិស្សិតប្រកាន់យកបញ្ហានេះ ។ អំពើប្រព្រឹត្តធ្វើទៅលើជនជាតិយួននៅក្នុងស្រុកខ្មែរ បានក្លាយជាប្រភពនៃការអាម៉ាស់ចំពោះរដ្ឋាភិបាលធីវ ពីព្រោះនៅក្នុងពេលជាមួយគ្នានោះ មានការផ្តល់ជំនួយយោធាទៅឲ្យរដ្ឋាភិបាលខ្មែរ ។

❑

គ្មានសេចក្តីរាយការណ៍ណាមួយរបស់យើងនៅវ៉ាស៊ិនតោន មុនពេលយើងចាកចេញធ្វើដំណើរ និងក៏គ្មានសេចក្តីរាយការណ៍ ព្រមទាំងការពិភាក្សាគ្នាដែលយើងបានធ្វើនៅស្រុកយួនកាលពីថ្ងៃទី២និងទី៣ឧសភា ដែលនិយាយអំពីការកើនឡើងនៃការកំហែងរបស់សត្រូវ ទៅលើកម្លាំងសហរដ្ឋអាមេរិកនៅវៀតណាមចេញពីកន្លែងជំរក ឬមួយក៏កំណើនកើនឡើងនៅខាងផ្នែកសត្រូវឯក្នុងប្រទេសកម្ពុជាទេ ។ ជាការពិតហើយ, នៅវ៉ាស៊ិនតោននិងសៃហ្គងបាននិយាយប្រាប់យើងថា ទំហំនៃកម្លាំងទ័ពវៀតណាមខាងជើងនិងវៀតកុងនៅក្នុងប្រទេសកម្ពុជា គឺស្ថិតនៅដដែលក្នុងរយ:ពេល៦ខែកន្លងមកនេះ សូម្បីតែគេពោលបន្ថែមថា ការប៉ាន់ស្មានជាប្រចាំនោះ មានចំនួនខ្ពស់ជាងនៅសៃហ្គងនិងវ៉ាស៊ិនតោន ដែលគេបានប៉ាន់ស្មានកាលពីខែមេសាថាមានចំនួនប្រហែល៤០,០០០នាក់ ហើយនិងនៅតែខ្ពស់ជាងនៅភ្នំពេញ ដែលកាលពីដើមខែឧសភា គេនិយាយថា កម្លាំងសត្រូវមានប្រហែល៥៥,០០០នាក់ទៅទៀត ។

ពួកមន្ត្រីយោធាសហរដ្ឋអាមេរិក ឃើញហាក់ដូចជាពុំបានចាត់ទុកកិច្ចប្រតិបត្តិការកងទ័ពវៀតណាមខាងត្បូង ឬសហរដ្ឋអាមេរិក នៅក្នុងប្រទេសកម្ពុជា ថាជាអំពើឈ្លានពាននោះទេ ។ ពួកគេពោលអះអាងថា តំបន់ព្រំដែនកម្ពុជា ជាកន្លែងស្ថិតនៅក្រោមការត្រួតត្រារបស់ពួកវៀតណាមខាងជើងនិងវៀតកុង និងជាទីកន្លែងដែលពួកអស់នោះនាំគ្នារត់ទៅជ្រកពួន ។ មន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិកម្នាក់បានអធិប្បាយថា ៖ «បើតាមការយល់ដឹងរបស់ខ្ញុំ ទីកន្លែងនេះជាទីកន្លែងពួកយួនពង្រីកទៅទិសខាងលិច» ។ ចំពោះរឿងការខូចខាតនៃពួកជនស៊ីវិលវិញ គេពុំបានលើកឡើងទាល់តែសោះ ។ ពេលយើងលើកសំនួរនេះនៅក្នុងពេលប្រជុំរាយការណ៍នៃបញ្ជាការជំនួយយោធានៅវៀតណាម (MACV), គេបានប្រាប់យើងថា គ្មានការខូចខាតដល់ជនស៊ីវិលទេ ពីព្រោះនៅទីកន្លែងដែលធ្វើប្រតិបត្តិការនោះ គ្មានជនស៊ីវិលរស់នៅទេ ។ ក៏ប៉ុន្តែនៅពេលយើងហោះទៅដល់មូលដ្ឋានមួយកំពុងឆេះជិតតំបន់«ផ្លែសន្ទូច»ស្រុកខ្មែរនាវេលារសៀលថ្ងៃនោះ យើងបានឃើញហ្វូងមនុស្សមួយក្រុម មានគ្នាប្រហែល៣០នាក់ នៅជិតភូមិមួយដែលយើងចុះ វេជ្ជបណ្ឌិតអាមេរិកាំងម្នាក់និយាយប្រាប់យើងថា គាត់បានទៅចូលភូមិកាលពីព្រឹកមិញនេះ ដើម្បីព្យាបាលជនស៊ីវិលរបួសមួយចំនួន និងបានប្រទះឃើញអ្នកផ្សេងទៀតស្លាប់ ។

នៅថ្ងៃដដែលនោះ, យើងបានទៅមើលជំរំជនភៀសខ្លួនទើបបង្កើតឡើងថ្មីមួយ នៅអានឡុក ខាងដីវៀតណាមខាងត្បូងតាមព្រំដែន ទល់មុខគ្នានឹងតំបន់«ផ្លែសន្ទូច» រួចហើយបាននិយាយជាមួយពួកអាណិកជនជាតិយួន ដែលធ្លាប់បានធ្វើការនៅក្នុងការិយាល័យចំការកៅស៊ូស្នួល ។ គាត់និយាយថា គ្រួសាររបស់គាត់នឹងគ្រួសារដទៃទៀតដែលមកពីស្នួលនិងពីចំការកៅស៊ូ បានភៀសខ្លួនរត់ចូលព្រៃ នៅពេលផ្សារស្នួលទទួលរងការវាយប្រហារពីយន្តហោះអាមេរិកាំង កាលពីថ្ងៃទី៤ឧសភា រួចហើយបានពួនលាក់ខ្លួននៅទីនោះ រហូតដល់ពេលកងទ័ពថ្មើរជើងអាមេរិកាំងទៅដល់នៅថ្ងៃទី៨ឧសភា និងដឹកពួកគេមកកាន់ទីនេះ ។ ជាការពិតប្រាកដណាស់, តំបន់«ជំពុះសេក» គឺជាទីកន្លែងមានមនុស្សរស់នៅច្រើនជាងតំបន់«ផ្លែសន្ទូច»ទៅទៀត ។

❑

វាគ្មានមន្ទិលសង្ស័យសោះឡើយ ដែលកងទ័ពបានចំណេញខ្លះៗក្នុងរយ:ពេលខ្លី ដូចជាអង្គទ័ពទី៤, អង្គទ័ពទី៣ និងអង្គទ័ពទី២ទិសខាងត្បូងវៀតណាមជាដើម ពីការកាត់ផ្តាច់ខ្សែទាក់ទងនិងស្បៀង, ការចាប់បានឧបករណ៍យោធា ហើយនិងទាហានសត្រូវជាច្រើនពាន់នាក់ត្រូវស្លាប់ ។ ពួកមន្ត្រីយោធាសហរដ្ឋអាមេរិកនៅសៃហ្គងបាននិយាយកាលពីដើមខែឧសភាថា ប្រតិបត្តិការនៅក្នុងស្រុកខ្មែរ ត្រូវផ្តល់ឲ្យពួកគេរហូតដល់៦ខែ ដើម្បីអនុញ្ញាតឲ្យវៀតណាមខាងត្បូង ពង្រឹងនូវលទ្ធភាពការពារខ្លួនឯង គឺពុំមែនមកពីការគ្រាន់តែចាប់បានឧបករណ៍មួយចំនួនយ៉ាងធំ ព្រមទាំងស្បៀងប៉ុណ្ណោះទេ តែពីព្រោះកម្លាំងបច្ចាមិត្តជាចាំបាច់ត្រូវបង្ខំឲ្យដកឃ្លាឆ្ងាយពីព្រំដែន ដែលនឹងបន្ធូរគំនាបសង្កត់ទៅលើភាគខាងត្បូងវៀតណាម ដែលមានអង្គទ័ពទី៣, អង្គទ័ពទី៤ ហើយនិងសង្កាត់យោធា ដែលជាកន្លែងមានប្រជាជនរស់នៅចំនួន៦៩ភាគរយ និងជាទីកន្លែងដែលពួកមន្ត្រីយោធាជឿថា សង្គ្រាមត្រូវឈ្នះឬក៏ត្រូវចាញ់ ។

គេគ្មានមន្ទិលសង្ស័យសោះឡើយ អំពីការរឹបអូសចាប់យកបាននូវឧបករណ៍យោធា ព្រមទាំងស្បៀងយ៉ាងសំខាន់ៗ ។ យើងបានទៅមើលកន្លែងលាក់អាវុធមួយ ដែលគេបានរកឃើញ ។ យើងបានឃើញស្តុកគេដាក់គរនៅលើដី អាវុធមកពីចិននិងសូវៀតយ៉ាងច្រើនលើសលប់, គ្រាប់រំសេវមកពីចិននិងឆេកូស្លូវ៉ាគី, ក្រណាត់មកពីចិននិងជប៉ុន, ចបប៉ែលមកពីអង់គ្លេស, ថ្នាំពេទ្យមកពីអាល្លឺម៉ង់ខាងកើត និងអង្ករមកពីកម្ពុជា ។ ទាហានអាមេរិកាំងម្នាក់ឈរយាមនៅកន្លែងស្តុកនិយាយប្រាប់យើងថា ៖ «ខ្ញុំគិតថាយួនខាងជើងកំពុងឈឺចាប់ ពេលខ្ញុំបានឃើញឥវ៉ាន់ផ្គត់ផ្គង់ទាំងអស់នេះ» ។

ការចំណេញខាងកងទ័ពមិនចំពោះមួយ តាមធម្មតាចេញមកពីផ្លែផ្កានៃប្រតិបត្តិការកងទ័ពវៀតណាមខាងត្បូងនៅកម្ពុជា ដែលផ្តល់នូវទំនុកទុកចិត្តដល់ខ្លួនឯងឡើងវិញ ដែលផុសចេញមកនៅវៀតណាមខាងត្បូង ។ ពួកមន្ត្រីសហរដ្ឋអាមេរិកភាគច្រើន ប្រមើមើលការវាយប្រហារនៃកងទ័ពវៀតណាមខាងត្បូងទៅលើជំរក ថាជា«ការលើកកម្លាំងចិត្តចំ-ពោះកងទ័ពវៀតណាមខាងត្បូង» ។ ពួកមន្ត្រីយួនក៏បាននិយាយផងដែរ ពីមោទនភាពដ៏ធំធេង និងអំពីការពេញចិត្តរបស់ខ្លួនចំពោះកិច្ចប្រតិបត្តិ-ការ ដោយសង្កត់ពាក្យថា ក្នុងករណីជាច្រើន កងទ័ពវៀតណាមខាងត្បូងបានធ្វើការប្រយុទ្ធ ដោយមានការជួយបន្តិចបន្តួចពីសហរដ្ឋអាមេរិក និងជាទូទៅខ្លួនគឺជាមុខព្រួញនៃការវាយប្រហាររបស់ក្រុមសម្ព័ន្ធមិត្ត ។

ជាការផ្ទុយទៅវិញ, ការចំណេញខាងកងទ័ពយ៉ាងខ្លីនេះ ពុំបានផ្តល់នូវសេចក្តីសង្ឃឹមអ្វីជាដុំកំភួន ដូចដែលគេចង់បាននោះទេ ។ នៅពេលដែលធ្វើសេចក្តីរាយការណ៍នេះ, គ្មានអ្នកទោសថ្នាក់ខ្ពស់ណាម្នាក់បានត្រូវគេរាយការណ៍ចាប់ខ្លួនបានសោះ ។ គ្មានទីបញ្ជាការកណ្តាលរបស់កង

ទ័ពវៀតកុងបានត្រូវរកឃើញដូចគ្នាដែរ ។ ពេលយើងត្រូវគេរាយការណ៍ប្រាប់នៅឯបញ្ជាការដ្ឋានជំនួយយោធានៅវៀតណាម កាលពីថ្ងៃទី៣ឧសភា, គេបានប្រាប់យើងថា ការវាយប្រហាររួមគ្នារវាងកងទ័ពវៀតណាមខាងត្បូងជាមួយសហរដ្ឋអាមេរិក ធ្វើឡើងនៅក្នុងតំបន់«ផ្លែសន្ទូច» ដែលមានឈ្មោះហៅថា «តួងតាង៤៣» ឬ «ជ័យជំនះទាំងមូល៤៣» គឺជាការប្រឆាំងផ្ទាល់ចំពោះ «ទីតាំងបញ្ជាការកណ្ដាលនៃទ័ពកុម្មុយនិស្តវៀតណាមខាងត្បូង (COSVN) នៅវៀតណាមខាងត្បូង» ។ មេបញ្ជាការជាន់ខ្ពស់អាមេរិកាំងម្នាក់នៅសមរភូមិនិយាយប្រាប់យើងថា ៖ គាត់សង្ឃឹមរកឃើញនិងកំទេចចោល«រោងល្ខោន» ដែលគេហៅថាទីបញ្ជាការដ្ឋាននៃកងកម្លាំងកុម្មុយនិស្តវៀតណាមខាងត្បូង ហើយនិងគាត់សង្ឃឹមថាជាបណ្ដាញនៅក្រោមដីយ៉ាងសម្ងាត់មួយ ។ ប្រាំមួយថ្ងៃក្រោយមក, បន្ទាប់ពីប្រតិបត្តិការនៅក្នុងស្រុកខ្មែរបានប្រព្រឹត្តអស់ចំនួន៩ថ្ងៃ, មន្ត្រីនៅកន្លែងធ្វើសេចក្ដីរាយការណ៍ប្រចាំបញ្ជាការជំនួយយោធាអាមេរិកាំងនៅវៀតណាម (MACV) បានលើកឡើង អំពីពេលវេលាវាយយកបាន«កន្លែងស្តុកភស្តុភារយ៉ាងធំមួយរបស់បច្ចាមិត្ត» តែពុំបាននិយាយសោះអំពីទីបញ្ជាការនៃទ័ពកុម្មុយនិស្តវៀតណាមខាងត្បូង (COSVN) ទេ ។ ដល់ដូច្នោះទៅ, ក្នុងរវាងមួយអាទិត្យ, ទីបញ្ជាការនៃកងទ័ពកុម្មុយនិស្តវៀតណាមខាងត្បូង ក៏ជ្រះបាត់ពីសេចក្ដីរាយការណ៍ទៅ គឺដូចជារលាយបាត់ស្រមោលពីតំបន់ព្រំដែនខ្មែរដូច្នោះដែរ ។

ភាគច្រើននៃពួកមន្ត្រីអាមេរិកាំងផ្ដល់ជាយោបល់ដល់យើងថា មានបច្ចាមិត្តមួយចំនួនយ៉ាងធំ ដែលគេរាយការណ៍មកថាត្រូវកងទ័ពវៀតណាមខាងត្បូងសម្លាប់នោះ តាមពិតគឺស្លាប់ដោយការបាញ់រះពីកាំភ្លើងយន្តនៃឧទ្ធម្ភាគចក្ររបស់អាមេរិកាំងទេវិញទេ ។ ពួកមន្ត្រីជាន់ខ្ពស់កងទ័ពសាធារណរដ្ឋវៀតណាម (ARVN) និយាយប្រាប់យើងថា ចំនួនប្រហែល១០ភាគនៃបច្ចាមិត្ត ដែលបានរាយការណ៍ត្រូវសម្លាប់ដោយកងទ័ពសាធារណរដ្ឋវៀតណាមនោះ គឺសម្លាប់ដោយ«កម្លាំងអាកាស» ពោលគឺស្លាប់ដោយការបាញ់រះកាំភ្លើងយន្តរបស់អាមេរិកាំង ។ តែពួកអ្នកសង្កេតការណ៍អាមេរិកាំងខ្លះបានគិតថា ចំនួនភាគរយនេះទាប។ យើងបានត្រូវគេនិយាយប្រាប់នៅក្នុងពេលប្រជុំរាយការណ៍ថា នៅថ្ងៃទី២៩មេសា ដែលជាថ្ងៃទី១នៃប្រតិបត្តិការរបស់វៀតណាមខាងត្បូងនៅក្នុងប្រទេសកម្ពុជានោះ, ចំនួន«ភាគច្រើន»នៃបច្ចាមិត្តដែលស្លាប់ គឺត្រូវស្លាប់ដោយសារកាំភ្លើងយន្តពីឧទ្ធម្ភាគចក្រ ។ វាជាការពិតហើយ ដែលការបាញ់សម្លាប់នោះចេញមកពីអាកាស ក៏ប៉ុន្តែបើតាមដឹងជាទូទៅ គេពិបាកមិនអាចបែងចែកកម្លាំងបច្ចាមិត្តពីជនស៊ីវិល ឬជនជាតិខ្មែរពីជនជាតិយួនបានទេ តែខាងទាហានសរុបថា មនុស្សស្លាប់ទាំងអស់នោះសុទ្ធជាបច្ចាមិត្ត ។

ចំពោះទំនុកចិត្តខ្លួនឯងនៃកងទ័ពសាធារណរដ្ឋវៀតណាម (ARVN) វិញ យើងសូមគូសបញ្ជាក់ថា សេចក្ដីរាយការណ៍នៃកងទ័ពសាធារណរដ្ឋវៀតណាម ជួនកាលឃើញហាក់ដូចជាចង់យកចំណេញទាំងអស់ទៅខាងខ្លួនឯង ថាជាប្រតិបត្តិការរបស់ខាងវៀតណាម ។ ជាឧទាហរណ៍ ប្រតិបត្តិការ«កំទេចថ្ម» (Rock Crusher) ដែលចាប់ផ្ដើមឡើងកាលពីថ្ងៃទី២៩មេសា នៅក្នុងតំបន់«ចំពុះសេក» បានត្រូវគេបកស្រាយនៅក្នុងអង្គប្រជុំរាយការណ៍ថា ជាប្រតិបត្តិការរបស់កងទ័ពសាធារណរដ្ឋវៀតណាមសុទ្ធសាធនិងគ្មានការចូលរួមចំណែកពីកងទ័ពអាមេរិកាំងទេ ទោះបីខាងសហរដ្ឋអាមេរិកជាអ្នកផ្ដល់ឧទ្ធម្ភាគចក្របញ្ជាត្រួតពិនិត្យបួនគ្រឿង និងការគាំទ្រខាងយុទ្ធសាស្ត្រខ្លះពីអាកាស ដូចជាការដឹកជញ្ជូនស្បៀង, ការគាំទ្រខាងកាំភ្លើងធំ និងការបាញ់កាំភ្លើងយន្តពីឧទ្ធម្ភាគចក្រជាដើមក៏ដោយ ។ ក្នុងការគាំទ្រផ្នែកកាំភ្លើងធំ, សហរដ្ឋអាមេរិកបានផ្ដល់ស្ទើរតែចំនួនពាក់កណ្ដាល នៃការបាញ់ផ្លោងទាំងអស់នោះ ។ លើសពីនេះទៅទៀត, ជាមួយកងទ័ពសាធារណរដ្ឋវៀតណាមក្នុងសមរភូមិកម្ពុជា គេឃើញមានទីប្រឹក្សាអាមេរិកាំង៤៣នាក់ ជាប់ពាក់ព័ន្ធជាមួយកិច្ចប្រតិបត្តិការ និងមានទីប្រឹក្សាអាមេរិកាំង២៣នាក់ផ្សេងទៀត ជួយធ្វើការនៅឯទីបញ្ជាការក្នុងប្រទេសវៀតណាម ។

ជាទីបញ្ចប់, មានពួកអ្នកសង្កេតការណ៍ខ្លះបានឲ្យយោបល់ថា ការធានាខ្លួនឯងនៃកងទ័ពសាធារណរដ្ឋវៀតណាមបែបនេះ ប្រហែលធ្វើឲ្យទៅជាការអះអាងដែលពុំអាចប្រកែកបាន ។ ទោះបីមានការយល់អំពីអាកប្បកិរិយាចាត់ទុកខ្លួនជា«អ្នកឈ្នះគេ»របស់កងទ័ពសាធារណរដ្ឋវៀតណាមក៏ដោយ អាកប្បកិរិយាបែបនេះប្រហែលនឹងបង្ហាញឲ្យឃើញនូវការចូលចិត្តខាងផ្នែកកងទ័ពនៃសាធារណរដ្ឋវៀតណាម ដែលចង់ប្រយុទ្ធតទល់ជាមួយពួកវៀតណាមខាងជើងនិងវៀតកុង នៅក្នុងទឹកដីខ្មែរ ជាជាងនៅក្នុងទឹកដីវៀតណាម ។ ជាការពិត, នៅក្នុងពេលដែលយើងចាកចេញពីវៀតណាម គឺនៅថ្ងៃទី១១ឧសភា, កងទ័ពសាធារណរដ្ឋវៀតណាមបានដំណើរការយ៉ាងល្អ ហួសពីកិរិតតំបន់ជំរកដែលស្ថិតនៅតាមបណ្ដោយព្រំដែនទៅទៀត ។ ថ្ងៃទី៨ឧសភា, ជាឧទាហរណ៍, កម្លាំងទ័ពរួមវៀតណាមនិងសហរដ្ឋអាមេរិក បានជំរុញកាណូតតូចៗរបស់ខ្លួនជាង១០០គ្រឿង ឲ្យឡើងតាមទន្លេមេគង្គ ។ ពេលនោះ កាណូតអាមេរិកាំងពុំបានចូលហួសពី២១.៧ម៉ែល៍ទេទៅក្នុងដីខ្មែរ តែកាណូតវៀតណាម បានឡើងរហូតចូលទៅដល់ក្រុងភ្នំពេញ និងហួសពីហ្នឹងថែមទៀត ។ ប្រតិបត្តិការនេះ ពីដំបូងឡើយគេបកស្រាយប្រាប់យើងថា ជាបេសកកម្មជួយសង្គ្រោះ គឺនៅក្នុងវត្ថុបំណងផ្ដល់ម្ហូបអាហារដល់ជនភៀសខ្លួនយួននៅតាមដងទន្លេមេគង្គ នឹងជួយដឹកជញ្ជូនជនភៀសខ្លួនផ្សេងទៀត ពីភ្នំពេញមកស្រុកយួន ។ ជាការពិតមែនហើយ ជនភៀសខ្លួនភាគច្រើនបានទទទួលនូវការដឹកជញ្ជូននេះ ។ ក៏ប៉ុន្តែនៅក្នុងពេលនោះផងដែរ កម្លាំងតាមទន្លេនេះបានបែកទៅកាន់ទិសផ្សេងៗទៀត ដោយរួមជាមួយកងទ័ពម៉ារីននិងកងទ័ពប៉ារ៉ា តភ្ជាប់គ្នានិងកងទ័ពជើងគោកខ្មែរនៅក្នុងខេត្តតាកែវ បានធ្វើការវាយប្រហារទៅលើកងទ័ពបច្ចាមិត្ត នៅខេត្តកំពង់ចាមដែលស្ថិតនៅទិសខាងជើងឆៀងខាងកើតក្រុងភ្នំពេញ ។ ចាប់តាំងពីអាទិត្យដំបូងនៃខែឧសភាមក គេឃើញមានប្រតិបត្តិការផ្សេងទៀត ដែលកងទ័ពសាធារណរដ្ឋវៀតវៀតណាម បានធ្វើយ៉ាងជ្រៅចូលទៅក្នុងទឹកដីខ្មែរ ។ ប្រតិបត្តិការទាំងអស់នេះ លែងមានទាក់ទងជាមួយជំរក ឬមួយក៏ជួយសង្គ្រោះដល់ជនភៀសខ្លួនទៀតហើយ ។៚

( កកន ៖ ថ្វីបើឯកសារនេះ ចេញពីប្រភពអាមេរិកាំងខាង<សេរីនិយម> មែនពិត តែយើងនៅតែចង់បង្ហាញឲ្យឃើញថា មូលហេតុដែលភ្លើងសង្គ្រាមវៀតណាមអាចឆាបឆេះចូលមកដល់ផ្ទះខ្មែរនេះ គឺមកពីនយោបាយខុសរបស់ស្ដេចសីហនុនៅក្នុងអំឡុងទសវត្ស៦០ គឺការងាកវេរនយោបាយអព្យាក្រឹតភាពរបស់ខ្មែរ ផ្ទៀងទៅខាងប្លុកកុម្មុយនិស្ត ពោលគឺយួន ចិន និងសូវៀត ដោយការអនុញ្ញាតឲ្យពួកយៀកកុង-យៀកណាមខាងជើងប្រើប្រាស់ទឹកដីខ្មែរ ស្ថិតនៅតាមបណ្ដោយព្រំដែនទិសខាងកើតធ្វើជាជំរកនិងជាមូលដ្ឋានទ័ព ។ ទោះបីស្ដេចសីហនុពុំបានសារភាពកំហុសនេះក៏ដោយ យើងបានបង្ហាញឯកសារជាច្រើនរួចមកហើយ និងបន្តទៅមុខទៀត អំពីការជាប់ពាក់ព័ន្ធនិងអំពីការផុងខ្លួនរបស់ស្ដេចសីហនុ ជាមួយសត្រូវស្ទួនជាតិរបស់ខ្មែរ រហូតដល់ការរួមដៃក្នុងអំពើ<ឃាតកម្ម>ប្រល័យពូជសាសន៍ខ្លួនឯងជាមួយពួកមេខ្មែរក្រហម ។ យើងសង្ឃឹមថា ឯកសារប្រវត្តិសាស្ត្រទាំងអស់នេះ នឹងបានជំនួយដល់ការត្រិះរិះពិចារណារបស់បងប្អូនរួមជាតិជាទីស្នេហា អំពីវាសនានៃមាតុភូមិយើង ) ។

( នៅមានត )

ទស្សនាវដ្តី
សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ

## ប្រទេសកម្ពុជា
## ខែឧសភា ឆ្នាំ១៩៧០

### សេចក្ដីរាយការណ៍រៀបចំឡើងដោយបុគ្គលិក សំរាប់ការប្រើប្រាស់នៃគណៈកម្មាធិការព្រឹទ្ធសភា ផ្នែកទំនាក់ទំនងការបរទេសសហរដ្ឋអាមេរិក

(បោះពុម្ពផ្សាយនៅថ្ងៃទី៧ មិថុនា ឆ្នាំ១៩៧០)

(បកប្រែក្រៅផ្លូវការ)

តមកពីលេខមុន...

## ទស្សនៈពីរដ្ឋាភិបាលក្រុងភ្នំពេញ

គឺជាការចង្អុលប្រាប់យើងដោយពួកអ្នកសង្កេតការណ៍ជាច្រើននៅក្នុងប្រទេសកម្ពុជាថា បើរដ្ឋាភិបាលលន់-នល់យល់ព្រមរក្សាសភាពការណ៍ដដែល ក្នុងការអនុញ្ញាតឲ្យវៀតណាមខាងជើងនិងវៀតកុងកាន់កាប់ជំរកនៅតាមបណ្ដោយព្រំដែនវៀតណាមខាងត្បូង និងបន្តសម្រួលផ្ដល់ស្បៀងដល់ពួកគេតាមរយៈបណ្ដាញជំនួញ... បើរដ្ឋាភិបាលថ្មីមិនធ្វើសកម្មអ្វីផ្សេងទៀត ដែលធ្វើឲ្យវៀតណាមខាងជើងប្រែទៅជាសត្រូវទេ និងបើកងទ័ពសាធារណរដ្ឋវៀតណាម (ARVN) មិនពង្រីកប្រតិបត្តិការឆ្លងកាត់ព្រំដែនរបស់ខ្លួន... នោះវៀតណាមខាងជើងនិងវៀតកុងក៏ប្រហែលមិនរុលចេញពីជំរករបស់ពួកគេ ចូលជ្រៅមកខាងក្នុងទឹកដីខ្មែរ និងចូលមកជិតទីក្រុងភ្នំពេញដែរ ។ រដ្ឋាភិបាលខ្មែរថ្មីក៏ប្រហែលមិនត្រូវប្រឈមមុខតទល់ជាមួយនឹងការគំរាមកំហែងយោធាដ៏ធ្ងន់ធ្ងរ និងការស្លាប់រស់របស់នគរ ព្រមទាំងមានកងទ័ពយួនដល់ទៅពីរក្រុមត្រូវមកប្រយុទ្ធប្រហារគ្នានៅលើទឹកដីរបស់ខ្លួនបែបយ៉ាងដូច្នេះឡើយ ។

ពត៌មានដែលមានការខ្វែងគំនិតគ្នានោះ គឺថាតើលន់-នល់សុខចិត្តឬមិនសុខចិត្តយកតាមកិច្ចព្រមព្រៀងខ្លះ ជាមួយវៀតណាមខាងជើងដូចគ្នានឹងការសម្រួលនៅក្រោមសីហនុឬយ៉ាងណា ។ ពួកអ្នកសង្កេតការណ៍ដែលមានការយល់ដឹងភាគច្រើនជឿថា វៀតណាមខាងជើងនិងរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នចង់ធ្វើការចរចា, តែខាងលន់-នល់ប្រកាន់ជំហរមិនព្រមសំរុះសំរួលទាល់តែសោះ ហើយពួកវៀតណាមខាងជើងដល់បន្តិចក្រោយមកក៏សរុបសេចក្ដីថា គេពុំអាចធ្វើការសំរុះសំរួលបានទេ ។ វាជាការពិតមែនហើយ, នៅក្នុងការជួបសន្ទនាគ្នារបស់យើង យើងរកពុំឃើញមាននរណាមួយនិយាយថា **លន់-នល់ដកជំហរថយចេញពីឱសានវាទថ្ងៃទី១២មិនារបស់គាត់ ដែលទាមទារឲ្យមានការដកកងទ័ពចេញទាំងមូលនោះឡើយ ហើយការយល់ឃើញរបស់យើងចេញពីការនិយាយគ្នាជាមួយពួកមន្ត្រីរដ្ឋាភិបាលខ្មែរគឺថា រដ្ឋាភិបាលនៅតែនិងសុខចិត្តធ្វើការចរចាជាមួយវៀតណាមខាងជើង លើប្រការដកកងទ័ពរបស់ខ្លួនទាំងមូលចេញតែប៉ុណ្ណោះ ។**

បើតាមទំនងមើលទៅ រដ្ឋាភិបាលខ្មែរហាក់ដូចជាគ្មាននរណាបានមកសុំការយល់ព្រមជាមុន អំពីការបើកការវាយប្រហារទៅលើជំរកនោះទេ សូម្បីតែប្រធានាធិបតីធីវនិយាយប្រាប់ទៅពួកអ្នកកាសែតនៅទីក្រុងព្រៃនគរ កាលពីថ្ងៃទី៨ឧសភាថា គាត់និងលន់-នល់បាន«ព្រមព្រៀងគ្នាជាគោលការណ៍» ទាក់ទងនឹងប្រតិបត្តិការកងទ័ពសាធារណរដ្ឋវៀតណាមនៅក្នុងស្រុកខ្មែរ ២ឬ៣ថ្ងៃមុនពេលប្រតិបត្តិការចាប់ផ្ដើមក៏ដោយ ។ ក្នុងករណីការវាយប្រហាររបស់អាមេរិកាំង ដែលចាប់ផ្ដើមកាលពីថ្ងៃទី១ឧសភា, រដ្ឋាភិបាលខ្មែរបានត្រូវប្រាប់ឲ្យដឹង រហូតដល់ក្រោយពេលចាប់ផ្ដើមបន្តិច ដោយសារមកពីមូលហេតុមានការយឺតយ៉ាវក្នុងការបញ្ជូនដំណឹងចេញមកពីវ៉ាស៊ិនតោន ។

ប្រតិកម្មរបស់ពួកមន្ត្រីរដ្ឋាភិបាលខ្មែរអំពីប្រតិបត្តិការនេះ ចំពោះយើងឃើញថា ហាក់ដូចជាមានការយល់ឃើញខុសគ្នា ។ ម្ខាងគេយល់ថា ពួកគេសប្បាយចិត្តដោយបានឃើញកម្លាំងផ្សេងទៀត ចុះមកជួយក្ដៅក្រហាយពួកគេ រួចហាក់ដូចជាសរុបថា ការវាយប្រហារទៅលើជំរក គឺប្រហែលដូចជាការតាំងចិត្តរបស់សហរដ្ឋអាមេរិក ជួយការពារអាយុជីវិតស្រុកទេសរបស់ខ្លួនយ៉ាងដូច្នោះ ។ ខាងម្ខាងទៀតគេយល់ថា គេមានអារម្មណ៍មិនស្រួលទាល់តែសោះ ចំពោះវត្តមានចំនួនយ៉ាងច្រើននៃកងទ័ពវៀតណាមខាងត្បូងនៅលើទឹកដីខ្មែរ ដោយសារមកពីមានការភ័យខ្លាចចំពោះអំពើឈ្លានពានរបស់យួនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រខ្មែរ ។

យើងមានការពេញចិត្តបន្តិចដែរនៅសៃហ្គុង លើផ្នែកខាងអាមេរិកាំងឬមួយខាងវៀតណាមខាងត្បូង អំពីលទ្ធភាពដែលថាខាងខ្មែរគេមានអារម្មណ៍យ៉ាងដូច្នេះនៅភ្នំពេញ ។ ក៏ប៉ុន្តែ យើងរកមិនឃើញមានភស្តុតាងត្រង់កន្លែងណា នៅសៃហ្គុងក៏ដូចគ្នានៅឯទីសមរភូមិ ដែលមានការគិតគូរថា ការជំរុញកម្លាំងបច្ចាមិត្តឲ្យឆ្ពោះទៅទិសខាងលិច ប្រហែលកាត់បន្ថយគំនាបសង្កត់នៅខាងយួន តែបង្កើនភាពតានតឹងនៅភ្នំពេញឯណោះ ដូចដែលពួកមន្ត្រីនៅភ្នំពេញបានចង្អុលបង្ហាញប្រាប់យើងសោះ ។ ដល់ដូច្នេះទៅ រឿងនេះហាក់ដូចជាការចំរុងចំរើននៅសៃហ្គុង តែបែរជាលិចលង់នៅខាងភ្នំពេញទៅវិញ ។

❑

ស្រុកខ្មែរបានចូលទៅក្នុងសង្គ្រាមឥណ្ឌូចិន ដោយមានកងទ័ពរបស់ខ្លួនតែ៣៥,០០០នាក់ប៉ុណ្ណោះ ។ ក្រោយភ្លាមមក ក៏រើសបានទាហានចំនួន១០,០០០នាក់ ហើយនិងដល់ពេលយើងទៅដល់ គេប្រមូលបានអ្នកស្ម័គ្រចិត្តចំនួន១៥០,០០០នាក់ថែមទៀត ។ ពួកគេហាក់ដូចជាគ្មានអាវុធអ្វីសំរាប់ពួកអ្នកស្ម័គ្រចិត្តទាំងអស់នេះសោះ ។ អ្វីដែលពួកគេមាននោះ គឺឧបករណ៍ខុសៗគ្នា សព្វៃស្រសព្វខ្លះបានមកពីចិន, ខ្លះបានមកពីបារាំង, ខ្លះបានមកពីសូវៀត និងខ្លះបានមកពីអាមេរិកាំង ។ កងទ័ពអាកាសមានយន្តហោះប្រយុទ្ធប្រហែល៩០គ្រឿងដូចជា Mig-17, T-28, C-47 និង Sky Raiders ។ យន្តហោះខ្លះនោះ មានលក្ខណៈចាស់ទ្រុឌទ្រោមខ្លាំងណាស់ ដែលពុំអាចហោះហើរបាន និងគ្មានគ្រឿងបន្លាស់ ឬការថែមទាំឲ្យបានគ្រប់គ្រាន់ទេ ។ ពួកមន្ត្រីរដ្ឋាភិបាលខ្មែរបាននិយាយប្រាប់យើងថា ពួកគេត្រូវការគ្រូបង្ហាត់បង្រៀន សំរាប់ប្រើប្រាស់នូវឧបករណ៍ដែលពួកគេបានសុំ ។ ប្រភពយោធាបស្ចឹមប្រទេសនិយាយថា ពួកគេមានសុទិដ្ឋិនិយមខ្លាំងណាស់ ហើយនិងត្រូវការជំនួយ ជាពិសេសឧបករណ៍ទាំងអស់នោះសុទ្ធតែចាស់ៗមុនជំនាន់ឆ្នាំ១៩៦០ រួចគ្មានពួកនាយទាហានខ្មែរបានមករៀនសូត្រនៅសហរដ្ឋអាមេរិកទេ ចាប់តាំងពីកាលនោះមក ។

រដ្ឋាភិបាលខ្មែរហាក់ដូចជាគ្មានបំណងចង់ស្វែងរកជំនួយពីអង្គការសេអាតូ (SEATO) ទេ ។ សីហនុបានបដិសេធការការពារពីអង្គការសេអាតូក្នុងឆ្នាំ១៩៥៦ ហើយបើតាមការជួបគ្នារបស់យើងជាមួយពួកមន្ត្រីរដ្ឋាភិបាលនៅភ្នំពេញនិយាយថា រដ្ឋាភិបាលថ្មីក៏គ្មានបំណងផ្លាស់ប្តូរគោលជំហររបស់ខ្លួន ដើរចេញពីរូបមន្តអព្យាក្រឹត្យភាពឡើយ ។

បញ្ហាជំនួយសេដ្ឋកិច្ច គឺពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហាជំនួយយោធា ។ ពួកមន្ត្រីរដ្ឋាភិបាលខ្មែរពិតជាជឿថា ដោយសារស្រុកទេសរបស់ខ្លួនមានសេដ្ឋកិច្ចមិនល្អ ហើយនិងដើម្បីទប់ទល់ជាមួយបច្ចាមិត្តឲ្យមានប្រសិទ្ធិភាព ពួកគេត្រូវការជំនួយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រស្ថាប័នយ៉ាងធំខាងកងទ័ព ។ បើតាមយើងយល់ ពួកគេហាក់ដូចជាជឿថា ភាគច្រើននៃជំនួយគឺចេញមកពីសហរដ្ឋអាមេរិក ទោះបីពួកគេមានសង្ឃឹមនៅក្នុងពេលនោះថា នឹងបានខ្លះពីប្រទេសជប៉ុន, អូស្ត្រាលី, ហ្វីលីពីន, ឥណ្ឌូណេស៊ី និងថៃក៏ដោយ ។

គេមានអារម្មណ៍យ៉ាងមាំ នៅក្នុងជួររដ្ឋាភិបាល ក៏ដូចនៅក្នុងចំណោមក្រុមបញ្ញវ័ន្តដែរថា នៅក្នុងស្ថានភាពបែបនេះ មានតែសហរដ្ឋអាមេរិក ប៉ុណ្ណោះ ដែលជួយខ្មែរថែរក្សាឯករាជភាព ប្រឆាំងនឹងអំពើឈ្លានពានពីខាងក្រៅបាន ។ តាមពិត, ពួកអ្នកសង្កេតការណ៍ខ្លះបានឲ្យយោបល់យើងថា លន់-នល់និងពួកសមាជិកផ្សេងទៀតនៃរដ្ឋាភិបាលរបស់គាត់ ប្រហែលមុខជាមិនសុខចិត្តធ្វើយ៉ាងដូច្នេះទេ នៅពេលគាត់ឡើងកាន់អំណាច ពីព្រោះមកពីគេជឿដល់ការគាំទ្រនៃសហរដ្ឋអាមេរិក ។ ភាគច្រើននៅភ្នំពេញគេជឿយ៉ាងដូច្នេះ ទោះបីរដ្ឋាភិបាលថ្មីសង្ឃឹមទៅលើជំនួយសេដ្ឋកិច្ចនិងយោធាពីសហរដ្ឋអាមេរិករួចហើយក៏ដោយ ។ ពួកគេជឿលើទឹកចិត្តល្អរបស់សហរដ្ឋអាមេរិក មុនពេលជំនួយសេដ្ឋកិច្ចនិងយោធាចំពោះខ្មែរ បានត្រូវកាត់ផ្តាច់តាមសំណូមពររបស់សីហនុកាលពីឆ្នាំ១៩៦៣ ហើយក៏ពីព្រោះសហរដ្ឋបានធ្វើជាច្រើនរួចមកហើយ ជួយដល់វៀតណាមខាងត្បូង ។ មានពលរដ្ឋខ្មែរច្រើនជាងម្នាក់បានធ្វើការសង្កេតយ៉ាងសុបសៅថា ៖ «បើយើងបានទម្លាក់សីហនុកាលពី២ឬ៣ឆ្នាំមុននោះ ម៉្លេះសមសហរដ្ឋអាមេរិកបានជួយយើងរួចទៅហើយ» ។

(នៅមានត)

ទស្សនាវដ្ដី
សម្លេងខ្មែរនៅបរទេស

# ឯកសារប្រវត្តិសាស្ត្រ

## ប្រទេសកម្ពុជា
## ខែឧសភា ឆ្នាំ១៩៧០

### សេចក្ដីរាយការណ៍រៀបចំឡើងដោយបុគ្គលិក សំរាប់ការប្រើប្រាស់នៃគណៈកម្មាធិការព្រឹទ្ធសភា ផ្នែកទំនាក់ទំនងការបរទេសសហរដ្ឋអាមេរិក

(បោះពុម្ពផ្សាយនៅថ្ងៃទី៧ មិថុនា ឆ្នាំ១៩៧០)

(បកប្រែក្រៅផ្លូវការ)

តមកពីលេខមុន...

### អាថ៌កំបាំងនៃជំនួយយោធាដល់កម្ពុជា

នៅពេលពួកយើងចាកចេញពីក្រុងភ្នំពេញ គឺថ្ងៃទី៨ឧសភា, រដ្ឋាភិបាលខ្មែរបានទទួលជំនួយយោធាបីជុំរួចទៅហើយ ដែលយើងបានដឹង ។ ជំនួយទាំងនោះគឺមាន ៖ កាំភ្លើងស្វ័យប្រវត្តិ AK-47 ចំនួន៦,០០០ដើម និងគ្រាប់, កាំភ្លើងអាមេរិកាំងធុន M-2 ចំនួន៧,២០០ដើម ហើយនិងទាហានខ្មែរកម្ពុជាក្រោមជាច្រើនពាន់នាក់ ដែលភាគច្រើននោះមានលក្ខណៈជាអ្នកស៊ីឈ្នួលធ្វើសង្គ្រាម ក្រោមកិច្ចសន្យាជាមួយសហរដ្ឋអាមេរិក ។ កងកម្លាំងពិសេសដែលគេហៅថា Civilian Irregular Defense Group -CIDG (បើយោងតាមសេចក្ដីរាយការណ៍ពីពួកអ្នកកាសែតនៅភ្នំពេញនិយាយថា បានមកដល់ចំនួន២១០០នាក់ តែប្រធានាធិបតីធីវ និយាយប្រាប់ពួកអ្នកកាសែតនៅសៃហ្គុនកាលពីថ្ងៃ៨ឧសភាថា ទាហានចំនួន៤,០០០នាក់បានបញ្ជូនចេញមករួចហើយ) ។ ។

កាំភ្លើង AK-47 ទាំងអស់នេះត្រូវបានគេនិយាយប្រាប់ថា ដឹកមកភ្នំពេញតាមជើងយន្តហោះនៃកងទ័ពអាកាសវៀតណាមខាងត្បូង ពីទីក្រុងសៃហ្គុន ចេញពីកន្លែងឃ្លាំងអាវុធដែលគេរឹបអូសយកបាននៅវៀតណាម ។ ពួកមន្ត្រីអាមេរិកាំងនៅភ្នំពេញនិយាយថា ពួកគេគ្មានពត៌មានពិស្ដារស្ដីអំពីការដឹកជញ្ជូនកាំភ្លើង AK-47 ទាំងអស់នេះទេ ហើយពួកគេប្រាប់យើងឲ្យទៅស៊ើបសួរនៅទីក្រុងសៃហ្គុនទៅ ។ គេបាននិយាយប្រាប់យើងឲ្យទៅជួបជាមួយពួកទាហានវៀតណាមខាងត្បូង ។ នៅក្នុងប្រជុំរាយការណ៍ជាទូទៅមួយនៃអគ្គសេនាធិការធិការកងទ័ពវៀតណាម, យើងបានសាកសួរឧត្តមសេនិយដ៏សំខាន់ម្នាក់ នៅក្នុងចំណោមឧត្តមសេនិយជាង១០នាក់ផ្សេងទៀតនៅទីក្នុងនោះ សុំឲ្យនិយាយប្រាប់យើងពិស្ដារអំពីរឿងនេះ ស្រាប់តែឧត្តមសេនិយរូបនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងថាគាត់ពុំបានដឹងអ្វីទាំងអស់អំពីរឿងកាំភ្លើង AK-47 នេះទេ ។ គាត់និយាយថា ពួកគេពុំអាចយកកាំភ្លើងចេញពីឃ្លាំងកងទ័ពសាធារណរដ្ឋវៀតណាម ដឹកទៅភ្នំពេញតាមយន្តហោះវៀតណាម ដោយគ្មានការដឹងឮពីគាត់យ៉ាងដូច្នេះបានឡើយ ។

ក្នុងការសុំចម្លើយបំភ្លឺថែមទៀតនៅឯស្ថានទូតក្រុងសៃហ្គុន និងនៅឯសេនាធិការដ្ឋានបញ្ជាការជំនួយយោធាសហរដ្ឋអាមេរិកនៅវៀតណាម (MACV) បាននិយាយប្រាប់យើងថា កាំភ្លើងដែលបានបញ្ជូនតាមយន្តហោះវៀតណាម គឺចេញពីឃ្លាំងកងទ័ពសាធារណរដ្ឋវៀតណាម ។ តែចំពោះគ្រប់ៗគ្នាដែលយើងបានជួបនិយាយជាមួយនៅឯស្ថានទូត និងនៅសេនាធិការដ្ឋានបញ្ជាការជំនួយយោធាសហរដ្ឋអាមេរិកនៅវៀតណាម រួមទាំងមន្ត្រីជាន់ខ្ពស់ផ្នែកខាងសម្ភារៈម្នាក់ ដែលគេបានចាត់ឲ្យមកឆ្លើយនឹងសំនួររបស់យើងនិយាយថា គាត់ពុំដឹងទេ ហើយបើសូម្បីតែដឹងក៏មិនដឹងថាមានកាំភ្លើងចំនួនប៉ុន្មានចេញពីឃ្លាំងអាមេរិកាំង ឬមានកាំភ្លើងចំនួនប៉ុន្មានចេញចេញពីឃ្លាំងយួនដែរ ។ តើគេទទួលបញ្ជាឲ្យធ្វើពីនរណាក៏មិនដឹង, តើការដឹកលើកទី១ទៅដល់ពេលណា, តើចំនួនកាំភ្លើងដែលខាងអាមេរិកាំងរឹបអូសយកបានមានចំនួនប៉ុន្មានដើម, តើខាងកងទ័ពសាធារណរដ្ឋវៀតណាមរឹបអូសយកបានមានប៉ុន្មានដើម...ហើយតើនៅក្នុងឃ្លាំងអាមេរិកាំង មានកាំភ្លើង AK-47 ប៉ុន្មានដើម ក៏គ្មាននរណាម្នាក់ដឹងពិតប្រាកដឡើយ ។

នៅក្នុងករណីកាំភ្លើង M-2 វិញ, សេនាធិការដ្ឋានបញ្ជាការជំនួយយោធាសហរដ្ឋអាមេរិកនៅវៀតណាម (MACV) មានចម្លើយយ៉ាងប្លែកអស្ចារ្យ ។ គេនិយាយប្រាប់យើងថា សេនាធិការដ្ឋានបញ្ជាការជំនួយយោធាសហរដ្ឋអាមេរិកនៅវៀតណាម (MACV) មិនអនុញ្ញាតឲ្យនិយាយពីរឿងនេះប្រាប់យើងទេ ហើយពួកគេបានឲ្យយោបល់យើង ទៅសាកសួរឯវ៉ាស៊ិនតោន ដោយសរសេរជាលាយលក្ខណ៍អក្សរទៅកាន់អគ្គបញ្ជាការកងទ័ពទៅ ។ ដូចគ្នានឹងករណីនៃពួកទាហានខ្មែរកម្ពុជាក្រោមដែរ, ពួកមន្ត្រីនៅភ្នំពេញ សុំឲ្យយើងទៅសាកសួរនៅសៃហ្គុន ។ តែដល់ពេលយើងសំណូមពរសុំសេចក្ដីរាយការណ៍ ពីសេនាធិការដ្ឋានបញ្ជាការជំនួយយោធាសហរដ្ឋអាមេរិកនៅវៀតណាម (MACV) ឬពីកងកម្លាំងពិសេស ផ្ដល់មកយើងយ៉ាងពិស្ដារ តើមានទាហានខ្មែរក្រោមប៉ុន្មាននាក់បានបញ្ជូនទៅស្រុកខ្មែរ, ដឹកទៅដល់លើកទី១ពេលណា, តើពេលណាសហរដ្ឋអាមេរិកឈប់បើកប្រាក់ខែឲ្យពួកគេ ហើយនិងតើសហរដ្ឋអាមេរិកនៅឬក៏អត់ចំណាយខាងអាវុធដល់ពួកគេ ។ ជាថ្មីម្ដងទៀតយើងបានត្រូវកងកម្លាំងពិសេសនៅសៃហ្គុនប្រាប់ថា ពួកគេគ្មានសិទ្ធិអ្វីនិយាយរាយការណ៍ប្រាប់យើងបានទេ ។

យើងបានរកឃើញនៅភ្នំពេញ អំពីការទៅដល់នៃទាហានខ្មែរក្រោម ដែលគេប្រទះឃើញនៅក្នុងរដ្ឋធានីខ្មែរជាលើកដំបូង ដោយអ្នកឆ្លើយឆ្លងសារពត៌មានម្នាក់ ដែលគាត់ធ្លាប់ស្នាក់នៅក្នុងស្រុកយួនរាប់ឆ្នាំ ។ គាត់និយាយបញ្ជាក់ថា គាត់បានឃើញទាហានខ្មែរពាក់ឯកសណ្ឋានអាមេរិកាំង ដើរនៅកណ្ដាលទីក្រុង ។ ពេលគាត់សួរជាភាសាអង់គ្លេសថា តើពួកអ្នកឯងមកពីស្រុកយួនឬ ? ខ្មែរនោះក៏ឆ្លើយតបវិញថា ៖ «ស្ដាប់មិនបានទេលោក, សុំសួរម្ដងទៀតមក» ។ ហើយដល់គាត់សួរបន្ត ជននោះឆ្លើយថា ៖ «គេមិនអនុញ្ញាតឲ្យខ្ញុំនិយាយឆ្លងឆ្លើយជាមួយអ្នកកាសែតទេលោក» ។ អ្នកកាសែតមានការពិបាកបន្តិចនឹងសរុបសេចក្ដី តាមរយៈចម្លើយរបស់ទាហានខ្មែរនោះ តែគាត់អាចដឹងថាពួកទាហានទាំងអស់នេះធ្វើការយ៉ាងជិតស្និទ្ធជាមួយកងទ័ពអាមេរិកាំង។ មានអ្នកកាសែតម្នាក់ទៀតបាននិយាយប្រាប់យើងថា គាត់បាននិយាយជាមួយទាហានខ្មែរម្នាក់ ទាហាននោះនិយាយប្រាប់គាត់ថា គាត់បានមកដល់ភ្នំពេញប្រហែល៤ទៅ៦អាទិត្យហើយ ដែលយើងអាចធ្វើការសន្និដ្ឋានថា ពួកគេបានទៅដល់ស្រុកខ្មែរ ទំនងនៅក្នុងខែមិនា ។

គេប្រហែលមានជំនួយផ្សេងទៀតរបស់យួនខាងត្បូង និងរបស់អា

មេរិកាំង ផ្តល់ដល់រដ្ឋាភិបាលខ្មែរ នៅពេលយើងចាកចេញពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែយើងមិនអាចរកដឹងថាជាជំនួយអ្វី ឬចេញពីប្រភពណាឡើយ ។ យើងបានឮ, ជាឧទាហរណ៍, ពីពួកអ្នកកាសែតនៅភ្នំពេញ ដែលទាំងអស់នោះសុទ្ធជាពួកអ្នកកាសែតមានបទពិសោធន៍និយាយថា ឧទ្ធម្ភាគចក្រធុន Chinook និង Huey បានឃើញចុះនៅក្នុងទីក្រុង ។ យើងបានទៅស្ថានទូត មុនពេលការចេញដំណើររបស់យើងពីភ្នំពេញ រួចហើយក៏បាននិយាយគ្នាអំពីរឿងនេះជាមួយភារ:ធារីខាងកងទ័ព ។ ពួកគេនិយាយថា ពួកគេពុំបានដឹងអ្វីទាំងអស់ អំពីឧទ្ធម្ភាគចក្រអាមេរិកាំងឬយួនខាងត្បូង ចុះនៅក្នុងរដ្ឋធានីទេ ។ ពួកគេបានឲ្យយោបល់ថា មើលទៅប្រហែលឧទ្ធម្ភាគចក្របារាំងធុន Alouette ទេដឹង ដែលខាងខ្មែរធ្លាប់មាន ហើយនិងប្រហែលយើងស្តាប់សម្លេងច្រឡំជាមួយ Huey ដែលខ្មែរពុំដែលមានទាល់តែសោះ ។

ស្រាប់តែនៅក្នុងពេលយើងកំពុងនិយាយគ្នានោះ, យើងបានឮសូរសម្លេងមិនច្រឡំសោះ គឺសម្លេងឧទ្ធម្ភាគចក្រដែលកំពុងហោះសំដៅជិតមកដល់ ។ យើងទាំងអស់គ្នាជាមួយភារ:ធារីកងទ័ព ក៏នាំគ្នាស្ទុះចេញទៅរៀនហាលនៃអាគារស្ថានទូត ដើម្បីមើលឧទ្ធម្ភាគចក្រ កំពុងហោះសំដៅចំពីលើយើង ក្នុងកំពស់តែប៉ុន្មានរយហ្វីតប៉ុណ្ណោះ ។ ភារ:ធារីក្នុងរំពេជនោះស្រាប់តែថ្លែងបញ្ជាក់ថា គឺជាឧទ្ធម្ភាគចក្រធុន Huey ។ ទោះបីយើងទាំងពីរនាក់មើលឃើញមិនសូវច្បាស់យ៉ាងណាក៏ដោយ តែគឺជាឧទ្ធម្ភាគចក្រប្រភេទនោះយ៉ាងពិតប្រាកដណាស់ ។ យើងបានសួរម្តងទៀតទៅខាងសៃហ្គុង ឲ្យពន្យល់យើងអំពីរឿងកើតឡើងនេះ តែពុំបានជោគជ័យអ្វីទាំងអស់ ។ អាថ៌កំបាំងនៅតែមានដដែល ពុំអាចយើងចាប់ថ្នាក់រកភស្តុតាងបាន ទាំងខាងអាមេរិកាំងក៏ដូចគ្នានឹងខាងយួនខាងត្បូងដែរ អំពីអ្វីដែលពួកគេកំពុងតែធ្វើនៅក្នុងស្រុកខ្មែរ ។

វាជាការជ្រុលលើសលប់ពេកហើយ ចំពោះពួកអាជ្ញាធរអាមេរិកាំងនៅសមរភូមិ ក្នុងការគ្រាន់តែផ្តល់ពត៌មានពិស្តារ ដល់ពួកអ្នកតំណាងខាងនីតិបញ្ញត្តិ អំពីជំនួយរបស់សហរដ្ឋអាមេរិក និងការពាក់ព័ន្ធនៃជំនួយវៀតណាម ចែករំលែកទៅឲ្យរដ្ឋាភិបាលខ្មែរ ។ បើប្រសិនណាពួកគេប្រាប់យើងយ៉ាងពិស្តារអំពីរឿងនេះ ហើយបញ្ជាក់ថាជាកិច្ចការសម្ងាត់ នោះប្រហែលគ្មានការពិភាក្សាគ្នាជាសាធារណ:អំពីរឿងនេះទេ ។ ក៏ប៉ុន្តែដែលជាការពិតនោះ ពត៌មានពិស្តារពុំបានផ្តល់ឲ្យយើងសោះ ។

ក្នុងបញ្ហាទំនាក់ទំនងរវាងខាងផ្នែកនីតិបញ្ញត្តិនិងនីតិប្រតិបត្តិនៅក្នុងទីលានសមរភូមិ គេប្រហែលពុំបានដឹងជាទូទៅទេថា អ្វីដែលពួកគេកំពុងអនុវត្តនៅស្រុកយួន តម្រូវឲ្យពួកមន្ត្រីខាងកងទ័ពនិងខាងស៊ីវិលសហរដ្ឋអាមេរិក ត្រូវធ្វើសេចក្តីរាយការណ៍ជាលាយល័ក្ខអក្សរ ជូនទៅខាងនីតិបញ្ញត្តិ ។ លើដំណើរទាំងពីរជើងនេះ ហើយនិងដំណើររបស់យើងចុងក្រោយទៅស្រុកយួនកាលពីខែធ្នូឆ្នាំ១៩៦៩, ពួកអ្នកជូនដំណើរជាទាហានរបស់យើង ក៏ដូចគ្នានឹងពួកមន្ត្រីយោធានិងស៊ីវិលដែរ គឺបានត្រូវគេឲ្យសរសេរជាកំណត់ហេតុ អំពីការនិយាយគ្នាជាមួយយើង និងរាយការណ៍អំពីថាតើយើងសួរសំនួរអ្វីខ្លះ ហើយអំពីថាពួកគេយល់ឃើញយ៉ាងណាដែរ ។ ពួកគេពុំបាននិយាយប្រាប់យើងយ៉ាងដូច្នេះទេ តែយើងបានប្រទះឃើញដោយចៃដន្យ នូវកំណត់ហេតុទាំងអស់នោះ នៅក្នុងសេចក្តីរាយការណ៍សំខាន់ៗប្រាំមួយខែក្រោយមក ដែលចង្អុលបញ្ជាក់ឲ្យឃើញថា មានភាពស្រដៀងគ្នាទៅនឹងអ្វីៗដែលបានកើតឡើង ។ ការសន្ទនារបស់យើងជាមួយពួកគេ ក៏បានក្លាយទៅជាឯកសារផ្លូវការ ទោះបីសេចក្តីរាយការណ៍ទាំងអស់នោះ និយាយអំពីអ្វីដែលប្រហែលបានកើតឡើង ឬមួយពុំដែលបានកើតឡើងទាល់តែសោះក៏ដោយ ។៚

( នៅមានត )